## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាសិក្សាបញ្ចប់ការសិក្សា

# ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន
# BMW AG

ស្រាវជ្រាវ ពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១


តាក់តែងឡើងដោយ

និស្សិតឈ្មោះ: **សេន មាសា**

**ជា តាំងជីម**

សាស្ត្រាចារ្យណែនាំ

លោក **ព្រុំ សុគុណា**


ថ្នាក់បរិញ្ញាបត្រ គណនេយ្យ

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## សារណាសិក្សាបញ្ចប់ការសិក្សា

# ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន

# BMW AG

ស្រាវជ្រាវ ពីថ្ងៃទី ២៧ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០២១


| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **សេន មាសា** | លោក **ព្រុំ សុគុណា** |
| **ជា តាំងជីម** | |
| ថ្នាក់បរិញ្ញាបត្រ គណនេយ្យ | ឆ្នាំចូលសិក្សា ២០១៧ |
| ជំនាន់ទី ១៦ | ឆ្នាំសរសេរសារណា ២០២១ |

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សេន មាសា** និង **ងា តាំងជីម** ជានិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រគណនេយ្យឆ្នាំទី ៤ ក្រុម A4A1 ជំនាន់ទី ១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសូមថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

លោកឪពុក និងអ្នកម្តាយ ដែលលោកអ្នកមានគុណដ៏ធំធេងទាំងទ្វេរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថ្នាក់ថ្នម ថែរក្សា អប់រំ ប្រៀនប្រដៅ ទូន្មាន ណែនាំយ៉ាងយកចិត្តទុកដាក់បំផុតតាំងពីកូនតូចរហូតដល់ធំពេញវ័យចម្រើនសេចក្តី ថែមទាំងទំនុកបម្រុងដល់កូនឲ្យទទួលបាននូវការសិក្សាមួយដ៏ល្អ និងក្លាយខ្លួនជាមនុស្សដែលមានចំណេះដឹង និងសុភាវធម៌ក្នុងសង្គម។ លោកទាំងទ្វេរតែងតែផ្តល់កម្លាំងកាយ និងចិត្តដល់កូនជានិច្ចទោះជាស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ គឺត្រូវតែខិតខំប្រឹងប្រែងរៀនសូត្រ ពុះពារ ឆ្លងកាត់ព្យុះភ្លៀង និងជម្នះរាល់ឧបសគ្គដើម្បីទទួលបានជោគជ័យនៅក្នុងជីវិតរបស់កូន។

ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកគ្រប់លំដាប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃខិតខំប្រឹងប្រែងបង្ហាត់បង្រៀន ប្រៀនប្រដៅ អប់រំ ទូន្មាន ណែនាំអស់ពីកម្លាំងកាយចិត្តដល់យើងខ្ញុំក្នុងរយៈពេលបួនឆ្នាំកន្លងមកនេះ ដោយពុំគិតពីការនឿយហត់ និងទុក្ខលំបាកនោះឡើយ។

លោកសាស្ត្រាចារ្យ **ព្រុំ សុគុណា** ដែលជាសាស្ត្រាចារ្យណែនាំនូវកិច្ចការស្រាវជ្រាវរបស់យើងខ្ញុំ។ លោកសាស្ត្រាចារ្យតែងតែផ្តល់នូវកម្លាំងចិត្ត អប់រំ ដាស់តឿន ក្រើនរំលឹក និងទាំងចំណាយពេលវេលាដ៏មានតម្លៃក្នុងការអប់រំ ណែនាំ ផ្តល់នូវគំនិតល្អៗ និងចំណេះដឹងជាច្រើនសម្រាប់យើងខ្ញុំយ៉ាងអស់អំពីចិត្ត ព្រមទាំងជួយកែសម្រួលនូវចំណុចខ្វះខាតដែលបានកើតមានឡើងលើសារណាមួយនេះផងដែរ។

បងប្អូន ប្រុសស្រី មិត្តភ័ក្តិ ព្រមទាំងមិត្តរួមថ្នាក់ទាំងអស់ដែលបានផ្តល់ជាកម្លាំងចិត្តក្នុងការសរសេរសារណានេះឡើង និងផ្តល់ជាមិតិរិះគន់ដើម្បីស្ថាបនារាល់កំហុសឆ្គងនានាដែលកើតមានឡើង។

ជាចុងបញ្ចប់នេះយើងខ្ញុំសូមថ្លែងអំណរគុណដល់ លោកអ្នកមានគុណ លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូគ្រប់ជាន់ថ្នាក់ បងប្អូន និងមិត្តភ័ក្តិទាំងអស់ ជួបប្រទះនូវប្រសិទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីទទួលបានការអប់រំ បណ្ដុះបណ្ដាល យកចិត្តទុកដាក់បំផុតពីសំណាក់លោកសាស្ត្រាចារ្យណែនាំ និងលោកគ្រូ អ្នកគ្រូ ធ្វើឲ្យយើងខ្ញុំទទួលបាននូវចំណេះដឹងមួយដែលពោរពេញទៅដោយគុណភាព និងគុណតម្លៃ តាមរយៈការសិក្សាកន្លងមករយៈពេលបួនឆ្នាំអាចឲ្យយើងយល់ដឹង និងស្គាល់យ៉ាងច្បាស់អំពីទ្រឹស្ដីមួយមួយចំនួនធំ ដែលទាក់ទងជាមួយនឹងជំនាញគណនេយ្យ។ ជាការពិតណាស់សាកលវិទ្យាល័យបានផ្ដល់ឱកាសឲ្យនិស្សិតធ្វើការ សិក្សាស្រាវជ្រាវដើម្បីសរសេរបាយការណ៍ ឬសរសេរសារណាបញ្ចប់ការសិក្សារបស់ខ្លួន ព្រមទាំងបានធ្វើការផ្ដល់នូវ ឱកាសឲ្យនិស្សិតយកទ្រឹស្ដីដែលបានសិក្សាកន្លងមក ទៅអនុវត្តផ្ទាល់ក្នុងការងារជាក់ស្ដែងនៅតាមស្ថាប័នផងដែរ។ របាយការណ៍ហិរញ្ញវត្ថុ គឺជារបាយការណ៍មួយដែលរៀបចំឡើងដើម្បីធ្វើការបង្ហាញព័ត៌មានអំពីប្រតិបត្តិការក្រុមហ៊ុន មានភាពរីកចម្រើនទៅមុខ ឬអន់ថយ។ របាយការណ៍ហិរញ្ញវត្ថុមានដូចជា តារាងតុល្យការ របាយការណ៍លទ្ធផល របាយការមូលធនកម្មសិទ្ធិ និងរបាយការណ៍ចលនាលំហូរសាច់ប្រាក់។ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុពិតជាមាន សារៈសំខាន់ណាស់សម្រាប់អ្នកវិនិយោគ វាបានផ្ដល់ព័ត៌មានឲ្យឃើញអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពអាជីវកម្ម មានដូចជា ចំណុចខ្លាំង និងចំណុចខ្សោយរបស់អង្គភាពអាជីវកម្មដែលវាដើរតួយ៉ាងសំខាន់ក្នុងការចូលរួមការ សម្រេចចិត្តរបស់អ្នកវិនិយោគ។ ម្យ៉ាងទៀត បច្ចុប្បន្ននេះយើងសង្កេតថាក្រុមហ៊ុនលក់រថយន្តម៉ាកល្បី BMW AG គឺ ជាក្រុមហ៊ុនដែលមានបច្ចេកវិទ្យាទំនើបមួយខាងផ្នែកយានយន្ត ដែលកំពុងតែមានការគាំទ្រយ៉ាងពេញទំហឹងពី សំណាក់ប្រជាជនទូទាំងពិភពលោកទទួលស្គាល់លើផ្នែកគុណភាពដែលជាភាពលេចធ្លោរបស់ក្រុមហ៊ុនមួយនេះ។ ហេតុដូច្នេះហើយទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទដែលស្ដីអំពី "ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុន BMW AG" មកសិក្សាស្រាវជ្រាវ។

យើងខ្ញុំសង្ឃឹមថាសៀវភៅដែលយើងខ្ញុំបានចងក្រងឡើងនេះនឹងជាជំនួយដល់និស្សិត មិត្តអ្នកអាន និងអ្នក វិនិយោគបានស្វែងយល់បន្ថែមពីការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុក្នុងការយកមកវិភាគរបាយការណ៍ហិរញ្ញវត្ថុ ដើម្បី ជាប្រយោជន៍ក្នុងការសិក្សា ឬសម្រាប់ប្រើប្រាស់ផ្សេងៗ។ ទោះបីមានការខិតខំចងក្រងសៀវភៅយ៉ាងណា យើងខ្ញុំជឿ ជាក់ថា សៀវភៅពិតជាមានលក្ខណៈពុំទាន់ល្អឥតខ្ចោះនៅឡើយទេ ទាំងការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ និង ខ្លឹមសារជាដើម។ យើងខ្ញុំរីករាយ និងស្វាគមន៍រាល់មតិយោបល់ដែលរិះគន់ និងកែលម្អក្នុងន័យស្ថាបនាពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ និងមិត្តអ្នកអានគ្រប់ពេលវេលាដោយក្ដីសោមនស្សបំផុត។

# មាតិកា

ទំព័រ

បញ្ជីតារាង ....................................................................................................iv

បញ្ជីរូបភាព ..................................................................................................... v

បញ្ជីក្រាហ្វិច ....................................................................................................vi

បញ្ជីឧបសម្ព័ន្ធ ..................................................................................................vii

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ.................................................................................១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ............................................................................... ២

៣.គោលបំណងនៃការស្រាវជ្រាវ................................................................................ ២

៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ............................................................... ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ................................................................................ ២

៦.វិធីសាស្ត្រស្រាវជ្រាវ ............................................................................................ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ................................................................................ ៣

## ជំពូកទី ១

## រំលឹកទ្រឹស្តី

១.១. របាយការណ៍ហិរញ្ញវត្ថុ.......................................................................................៥

១.១.១. និយមន័យរបាយការណ៍ហិរញ្ញវត្ថុ ......................................................................៥

១.១.២. ទម្រង់របាយការណ៍ហិរញ្ញវត្ថុ ...........................................................................៦

១.១.២.១. របាយការណ៍លទ្ធផល (Income Statement) ...................................................៦

១.១.២.២. របាយការណ៍ប្រាក់ចំណេញរក្សាទុក (Retained Earnings Statement)............................ ៧

១.១.២.៣. តារាងតុល្យការ (Balance Sheet)..................................................................... ៧

១.១.២.៤. របាយការណ៍ចលនាលំហូរសាច់ប្រាក់ (Statement of Cash Flows)...............................៨

១.២. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ...............................................................................៩

១.៣. គោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ.......................................................... ១០

១.៤ ឧបករណ៍វិភាគរបាយការណ៍ហិរញ្ញវត្ថុ ..... ១០
១.៤.១.ការវិភាគតាមជួរឈរ ..... ១០
១.៤.២. ការវិភាគតាមជួរដេក ..... ១១
១.៤.៣. ការវិភាគតាមអនុបាត ..... ១១
១.៤.៣.១. អនុបាតសន្ទនីភាព ..... ១២
១.៤.៣.២. អនុបាតនៃលទ្ធភាពទូទាត់បំណុល ..... ១៤
១.៤.៣.៣. អនុបាតនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ ..... ១៦

## ជំពូកទី ២

## ស្ថានភាពទូទៅរបស់ក្រុមហ៊ុន BMW AG

២.១ប្រវត្តិរបស់ក្រុមហ៊ុន BMW ..... ១៩
២.២.បេសកម្មរបស់ BMW ..... ២១
២.៣.ចក្ខុវិស័យរបស់ BMW ..... ២១
២.៤.គុណតម្លៃរបស់ BMW ..... ២១
២.៥.និមិត្តសញ្ញា ..... ២២
២.៦.ផលិតផល BMW AG ..... ២៤
២.៧.ទីស្នាក់ការរបស់ក្រុមហ៊ុន BMW ..... ២៤
២.៨.រចនាសម្ព័ន្ធ BMW AG ..... ២៥
២.៩.សកម្មភាពអាជីវកម្ម BMW AG ..... ២៧
២.១០.ដៃគូប្រកួតប្រជែងរបស់ក្រុមហ៊ុន BMW ..... ២៩

## ជំពូកទី ៣

## ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG


៣.១. ការវិភាគតាមជួរដេក........................................ ៣២

៣.១.១. ការវិភាគតាមជួរដេកលើរបាយការណ៍លទ្ធផល........................................ ៣២

៣.១.២. ការវិភាគតាមជួរដេកលើតារាងតុល្យការ........................................ ៣៣

៣.២. ការវិភាគតាមជួរឈរ........................................ ៣៥

៣.២.១. ការវិភាគតាមជួរឈរលើរបាយការណ៍លទ្ធផល........................................ ៣៥

៣.២.២. ការវិភាគតាមជួរឈរលើតារាងតុល្យការ........................................ ៣៧

៣.៣. ការវិភាគតាមអនុបាត........................................ ៣៩

៣.៣.១. អនុបាតសន្ទនីយភាព........................................ ៣៩

៣.៣.២. អនុបាតនៃលទ្ធភាពទូទាត់បំណុល........................................ ៤៥

៣.៣.៣. អនុបាតលទ្ធភាពស្វែងរកប្រាក់ចំណេញ........................................ ៤៩

៣.៤.លទ្ធផលនៃការវិភាគ........................................ ៥៦


## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍


១.សេចក្ដីសន្និដ្ឋាន........................................ ៥៨

២.អនុសាសន៍........................................ ៥៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង


តារាងទី១៖ របាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន xxx ........................................................................................................៦
តារាងទី២៖ របាយការណ៍ប្រាក់ចំណេញរក្សាទុករបស់ក្រុមហ៊ុន xxx.................................................................................. ៧
តារាងទី៣៖ តារាងតុល្យការរបស់ក្រុមហ៊ុន xxx.................................................................................................................៨
តារាងទី៤៖ របាយការណ៍ចលនាលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន xxx ...........................................................................៩
តារាងទី៥៖ ការវិភាគតាមជួរដេកលើរបាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន BMW AG............................... ៣២
តារាងទី៦៖ ការវិភាគតាមជួរដេកលើតារាងតុល្យការរបស់ក្រុមហ៊ុន BMW AG ........................................ ៣៣
តារាងទី៧៖ ការវិភាគតាមជួរឈរលើរបាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន BMW AG ...............................៣៥
តារាងទី៨៖ ការវិភាគតាមជួរឈរលើតារាងតុល្យការរបស់ក្រុមហ៊ុន BMW AG ........................................ ៣៧
តារាងទី៩៖ អនុបាតចរន្តរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ .......................................៣៩
តារាងទី១០៖ អនុបាតរហ័សរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ .................................. ៤០
តារាងទី១១៖ អនុបាតបង្វិលជុំនៃឥណទេយ្យរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០............. ៤១
តារាងទី១២៖ អនុបាតចំនួនថ្ងៃនៃការបង្វិលឥណទេយ្យរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ៤២
តារាងទី១៣៖ អនុបាតបង្វិលជុំនៃសន្និធិរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ..................៤៣
តារាងទី១៤៖ អនុបាតចំនួនថ្ងៃនៃការលក់សន្និធិរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០.......... ៤៤
តារាងទី១៥៖ អនុបាតបំណុលធៀបនឹងទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ .... ៤៥
តារាងទី១៦៖ អនុបាតបំណុលធៀបមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០.............. ៤៦
តារាងទី១៧៖ អនុបាតមេគុណមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ .....................៤៧
តារាងទី១៨៖ អនុបាតនៃលទ្ធភាពទូទាត់ការប្រាក់របស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០........ ៤៨
តារាងទី១៩៖ អនុបាតប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ .................. ៥០
តារាងទី២០៖ អនុបាតបង្វិលទ្រព្យសកម្មរបស់ក្រុមហ៊ុនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ៥១
តារាងទី២១៖ អនុបាតផលចំណេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ .......៥២
តារាងទី២២៖ អនុបាតផលចំណេញធៀបនឹងមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ .៥៣
តារាងទី២៣៖ អនុបាតប្រាក់ចំណេញក្នុងមួយហ៊ុនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០....... ៥៤
តារាងទី២៤៖ អនុបាតថ្លៃជាមួយប្រាក់ចំណេញរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០.......... ៥៥

# បញ្ជីរូបភាព


រូបភាពទី ១ ៖ Gustav Otto (កើតនៅ ថ្ងៃទី ១២ ខែមករា ឆ្នាំ ១៨៨៣) ............................................. ១៩

រូបភាពទី ២ ៖ Karl Rapp (កើតនៅ ថ្ងៃទី ២៤ ខែសីហា ឆ្នាំ ១៨៨២) ............................................. ១៩

រូបភាពទី ៣ ៖ Franz Josef Popp (កើតនៅ ថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៨៨៦) ............................................. ១៩

រូបភាពទី ៤ ៖ Camillo Castiglioni (កើតនៅ ថ្ងៃទី ២២ ខែតុលា ឆ្នាំ១៨៧៩) ............................................. ១៩

រូបភាពទី ៥ ៖ ការវិវត្តន៍នៃនិមិត្តសញ្ញារបស់ក្រុមហ៊ុន BMW ពីឆ្នាំ ១៩១៧ - ២០២០ ............................................. ២២

រូបភាពទី ៦ ៖ BMW AG Subsidiaries ............................................. ២៣

រូបភាពទី ៧ ៖ ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន BMW AG ទីក្រុង Munich ប្រទេសអាល្លឺម៉ង់ ............................................. ២៤

រូបភាពទី ៨ ៖ រចនាសម្ព័នដឹកនាំ BMW ............................................. ២៦

រូបភាពទី ៩ ៖ គំរូនៃប្រព័ន្ធអនុលោមភាពក្រុមហ៊ុន BMW Group ............................................. ២៧

# បញ្ជីក្រាហ្វិច

ក្រាហ្វិចទី១៖ អនុបាតចរន្តរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ........................................ ៤០
ក្រាហ្វិចទី២៖ អនុបាតរហ័សរបស់ក្រុមហ៊ុន BMW AG ឆ្នាំ២០១៩ និងឆ្នាំ ២០២០ ........................................ ៤១
ក្រាហ្វិចទី៣៖ អនុបាតបង្វិលជុំនៃឥណទេយ្យរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ............. ៤២
ក្រាហ្វិចទី៤៖ អនុបាតចំនួនថ្ងៃនៃការបង្វិលឥណទេយ្យរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០.៤៣
ក្រាហ្វិចទី៥៖ អនុបាតបង្វិលជុំនៃសន្និធិរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០...................... ៤៤
ក្រាហ្វិចទី៦៖ អនុបាតចំនួនថ្ងៃនៃការលក់សន្និធិក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ................. ៤៥
ក្រាហ្វិចទី៧៖ អនុបាតបំណុលធៀបនឹងទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០..... ៤៦
ក្រាហ្វិចទី៨៖ អនុបាតបំណុលធៀបនឹងមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០.......... ៤៧
ក្រាហ្វិចទី៩៖ អនុបាតមេគុណមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ...................... ៤៨
ក្រាហ្វិចទី១០៖ អនុបាតនៃលទ្ធភាពទូទាត់ការប្រាក់របស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ២០២០ ...... ៤៩
ក្រាហ្វិចទី១១៖ អនុបាតប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ................ ៥០
ក្រាហ្វិចទី១២៖ អនុបាតបង្វិលទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ ................. ៥១
ក្រាហ្វិចទី១៣៖ អនុបាតផលចំណេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០..... ៥២
ក្រាហ្វិចទី១៤៖ អនុបាតប្រាក់ចំណេញធៀបមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ .... ៥៣
ក្រាហ្វិចទី១៥៖ អនុបាតប្រាក់ចំណេញក្នុងមួយហ៊ុនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០..... ៥៤
ក្រាហ្វិចទី១៦៖ អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០.... ៥៥

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១៖ របាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន BMW AG.............................................................១

ឧបសម្ព័ន្ធទី២៖ តារាងតុល្យការរបស់ក្រុមហ៊ុន BMW AG ....................................................................... ២

ឧបសម្ព័ន្ធទី៣៖ ចំនួនភាគហ៊ុនដែលបានបោះផ្សាយ និងការបែងចែកភាគលាភរបស់ក្រុមហ៊ុន BMW AG.........៤

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ទោះជាបច្ចុប្បន្ននេះពិភពលោកកំពុងជួបបញ្ហាវិបត្តិកូវីដ ១៩ មានវិស័យមួយចំនួនបានធ្លាក់ចុះ ហើយក៏មានវិស័យមួយចំនួននៅតែរីកចម្រើន។ ហេតុដូចនេះហើយទើបបណ្តាលឲ្យចិត្តអ្នកវិនិយោគជាច្រើនធ្វើការវិនិយោគទៅលើវិស័យផ្សេងៗគ្នា។ ក្នុងនោះផងដែរ បើយើងក្រឡេកមកមើលវិស័យសេដ្ឋកិច្ចឃើញថាកំពុងមានភាពជឿនលឿនគួរឲ្យកត់សម្គាល់។ ក្រុមហ៊ុនធំៗជាច្រើនបានពង្រីកសាខាអាជីវកម្មរបស់ខ្លួនសឹងតែគ្រប់ប្រទេសលើពិភពលោក។ ក្រុមហ៊ុនទាំងអស់នោះកំពុងធ្វើការយ៉ាងសកម្ម ដើម្បីឲ្យអាជីវកម្មរបស់ខ្លួនកាន់តែអាចលេចមុខលើទីផ្សារជាច្រើន និងហេតុផលមួយទៀតក៏ដើម្បីស្វែងរកអ្នកវិនិយោគទុន មកវិនិយោគលើក្រុមហ៊ុនខ្លួន។ ជាធម្មតា មុននឹងធ្វើការសម្រេចចិត្តវិនិយោគលើក្រុមហ៊ុនណាមួយ អ្នកវិនិយោគត្រូវដឹងអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននោះជាមុនសិន ដោយធ្វើការពិនិត្យទៅលើរបាយការណ៍ហិរញ្ញវត្ថុយ៉ាងម៉ត់ចត់បំផុតដើម្បីជៀសវាងនូវការជួបវិបត្តិផ្សេងៗ។ របាយការណ៍ហិរញ្ញវត្ថុមានសារៈសំខាន់ណាស់សម្រាប់អោយក្រុមហ៊ុនបង្ហាញដល់អ្នកវិនិយោគ ព្រោះថាការរៀបចំរបាយការណ៍ហិរញ្ញវត្ថុបានត្រឹមត្រូវ ការអនុវត្ត និងលទ្ធផលដែលក្រុមហ៊ុនទទួលបានជាសញ្ញាបង្ហាញពីដំណើរការរបស់ក្រុមហ៊ុន ជាពិសេសព័ត៌មានហិរញ្ញវត្ថុដែលទទួលបានពីការវិភាគរបាយការណ៍ហិរញ្ញវត្ថុនេះមានប្រយោជន៍ណាស់ចំពោះអ្នកវិនិយោគ ដើម្បីយកជាជំនួយក្នុងការសម្រេចចិត្តវិនិយោគឲ្យកាន់តែមានប្រសិទ្ធភាព។

បើយើងក្រឡេកទៅមើលវិស័យផលិតរថយន្តវិញ គឺឃើញថាកំពុងតែមានការប្រកួតប្រជែងខ្លាំងនៅជុំវិញសាកលលោក។ ក្នុងនោះដែរ គឺមានក្រុមហ៊ុនមួយដែលជាក្រុមហ៊ុនផលិតរថយន្តដែលកំពុងមានការរីកចម្រើនខ្លាំង និងជាក្រុមហ៊ុនមួយដែលត្រូវបានគេទទួលស្គាល់ថា ជាក្រុមហ៊ុនដ៏មានប្រជាប្រិយភាពនៅក្នុងចំណោមក្រុមហ៊ុនជាច្រើនទៀតក្នុងពិភពលោក នោះគឺក្រុមហ៊ុន BMW AG។ ក្រុមហ៊ុន BMW AG បានបង្កើតឡើងជាយូរណាស់មកហើយ មកទល់បច្ចុប្បន្ននេះ ក្រុមហ៊ុនមាន មានអាយុកាល ១០៤ឆ្នាំ និងមានផលិតផលជាច្រើនប្រភេទដូចជាម៉ាស៊ីនយន្តហោះ ម៉ូតូ រថយន្ត និងប្រាំងផ្លូវដែក ចំពោះការផលិតរថយន្តមានបីប្រេន គឺ BMW Mini Rolls-Royce ហើយប្រេននីមួយៗមានផលិតរថយន្តជាច្រើនម៉ាក ដោយការផលិតមានគុណភាពខ្ពស់ រួមនឹងភាពល្បីឈ្មោះរបស់ក្រុមហ៊ុន បានធ្វើអោយក្រុមហ៊ុនទទួលបានការគាំទ្រជាច្រើនពីសំណាក់អតិថិជន។ ដោយមើលឃើញពីចំណុចសំខាន់ព្រមទាំងការរីកចម្រើនរបស់ក្រុមហ៊ុន ក៏ដូចជាសារៈសំខាន់នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ ហេតុដូច្នេះហើយទើបក្រុមយើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវទៅលើប្រធានបទ "ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG" ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

សម្រាប់អ្នកវិនិយោគ ព័ត៌មានហិរញ្ញវត្ថុរបស់អង្គភាពអាជីវកម្មមួយ ដើរតួយ៉ាងសារៈសំខាន់ និងចាំបាច់ណាស់ក្នុងការចូលរួមបញ្ចៀស ឬកាត់បន្ថយហានីភ័យលើការវិនិយោគរបស់ខ្លួន។ នៅក្នុងការស្រាវជ្រាវលើការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG យើងខ្ញុំចង់ដឹងថា៖ (១) តើក្រុមហ៊ុនមានលទ្ធភាពសងបំណុលរយៈពេលខ្លី និងរយៈពេលវែងបែបណានៅឆ្នាំ ២០២០ បើធៀបនឹងឆ្នាំ ២០១៩? (២) តើសមត្ថភាពស្វែងរកប្រាក់ចំណេញរបស់ក្រុមហ៊ុនមានយ៉ាងដូចម្តេចដែរ? (៣) តើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានចំណុចខ្លាំង និងចំណុចខ្សោយបែបណានៅឆ្នាំ ២០២០ បើធៀបនឹងឆ្នាំ ២០១៩?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះគឺចង់សិក្សាពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG ដែលជាប្រយោជន៍សម្រាប់អ្នកវិនិយោគ រួមមាន៖

- ស្វែងយល់ស្ថានភាពទូទៅនៃក្រុមហ៊ុន BMW AG។
- ស្វែងយល់ពីលទ្ធភាពទូទាត់បំណុលរយៈពេលខ្លី និងរយៈពេលវែងរបស់ក្រុមហ៊ុន BMW AG។
- ស្វែងយល់ពីសមត្ថភាពស្វែងរកប្រាក់ចំណេញរបស់ក្រុមហ៊ុន BMW AG។
- ស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG។

## ៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺផ្តោតទៅលើស្ថានភាពទូទៅ និងការវិភាគផ្ទាល់ទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG។ ការស្រាវជ្រាវនេះគឺប្រើប្រាស់ទិន្នន័យរបស់ក្រុមហ៊ុន BMW AG ត្រឹមតែរយៈពេលពីរឆ្នាំចុងក្រោយ គឺឆ្នាំ ២០១៩ និងឆ្នាំ ២០២០។ ម៉្យាងទៀតការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺយើងវិភាគទៅតាមជួរដេក ជួរឈរ និងតាមអនុបាតរបស់ក្រុមហ៊ុនក្នុងឆ្នាំ ២០២០ ប្រៀបនឹងឆ្នាំ ២០១៩។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តល់អត្ថប្រយោជន៍ដូចជា:

- ជាកម្រងឯកសារទុកសម្រាប់និស្សិតជំនាន់ក្រោយ អាចធ្វើការស្វែងយល់បន្ថែមទៅលើការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។
- ផ្តល់ព័ត៌មានអំពីចំណុចខ្លាំង និងខ្សោយរបស់ក្រុមហ៊ុន ដែលជាជំនួយដល់អ្នកវិនិយោគដែលមានបំណងវិនិយោគលើមូលប័ត្របំណុល ឬភាគហ៊ុនរបស់ក្រុមហ៊ុន។

- ការស្រាវជ្រាវនេះផ្តល់ជាការយល់ដឹង និងអនុវត្តជាក់ស្តែងបន្ថែមទៅលើមេរៀនទ្រឹស្តីដែលរៀនកន្លងមក។

## ៦.វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការស្រាវជ្រាវលើប្រធានបទនេះ ព័ត៌មានសំខាន់ៗរបស់ក្រុមហ៊ុន BMW AG ដែលត្រូវយកមកសិក្សាស្វែងយល់នោះពឹងផ្អែកលើទិន្នន័យបន្ទាប់បន្សំដែលជាទិន្នន័យដែលមានស្រាប់ ដែលក្រុមយើងខ្ញុំប្រមូលចេញពី៖

- របាយការណ៍ហិរញ្ញវត្ថុដកស្រង់ចេញពីគេហទំព័រផ្ទាល់របស់ក្រុមហ៊ុន BMW AG
- តម្លៃទីផ្សារភាគហ៊ុនដែលយកចេញពីគេហទំព័រផ្សេងដែលទាក់ទងជាមួយក្រុមហ៊ុន

**ការវិភាគ:** តាមរយៈការប្រើប្រាស់ឧបករណ៍វិភាគតាមជួរដេក ជួរឈរ និងអនុបាត គឺដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងធាតុមួយ ជាមួយនឹងធាតុមួយទៀតក្នុងរបាយការណ៍ហិរញ្ញវត្ថុ ក្នុងគោលបំណងស្វែងយល់ពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅឆ្នាំ ២០២០ ដោយធ្វើការប្រៀបធៀបនឹងឆ្នាំ ២០១៩។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- **សេចក្តីផ្តើម៖** លំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិធីសាស្ត្រនៃការស្រាវជ្រាវ។
- **ជំពូកទី១៖ រំលឹកទ្រឹស្តី** យើងដែលរៀបរាប់អំពីសញ្ញាណទូទៅរបស់របាយការណ៍ហិរញ្ញវត្ថុ ទ្រឹស្តីរបស់អ្នកស្រាវជ្រាវមួយចំនួនពីរបាយការណ៍ហិរញ្ញវត្ថុ និងដំណើរការក្នុងការវិភាគអាជីវកម្ម។
- **ជំពូកទី២៖ ស្ថានភាពទូទៅរបស់ក្រុមហ៊ុន BMW AG** ដែលបានបង្ហាញពីព័ត៌មានទូទៅរបស់ក្រុមហ៊ុន និងផលិតផលរបស់ក្រុមហ៊ុន។
- **ជំពូកទី៣៖ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG** ដែលត្រូវបានសិក្សាពីការវិភាគលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនពីមូលហេតុ និងបញ្ហាដែលកើតមានឡើងបន្ទាប់ពីធ្វើការវិភាគរួច។
- **សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** គឺជាផ្នែកចុងក្រោយនៃសារណោដែលសង្ខេបឡើងវិញពីការស្រាវជ្រាវ និងការផ្តល់អនុសាសន៍។

# រចនាសម្ព័ន្ធនៃការស្រាវជ្រាវ



# ជំពូកទី១
# រំលឹកត្រីស្តី

# ជំពូកទី១
# រំលឹកទ្រឹស្តី

នៅក្នុងជំពូកទី១ នៃការសិក្សានេះ យើងធ្វើការរំលឹកទ្រឹស្តីដែលពាក់ព័ន្ធមានដូចជា របាយការណ៍ហិរញ្ញវត្ថុ និងទម្រង់របស់វា ហើយយើងក៏បានបង្ហាញផងដែរ អំពីឧបករណ៍ដែលយកមកប្រើប្រាស់សម្រាប់ធ្វើការវិភាគទៅលើរបាយការណ៍ ដែលទាំងនោះមានដូចជា ការវិភាគតាមទំហំរួម ការវិភាគតាមឆ្នាំគោល និងការវិភាគតាមអនុបាត។

## ១.១. របាយការណ៍ហិរញ្ញវត្ថុ

### ១.១.១. និយមន័យរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយគណនេយ្យកររៀងរាល់ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។ របាយការណ៍ហិរញ្ញវត្ថុជាមធ្យោបាយទំនាក់ទំនងព័ត៌មានចំពោះអ្នកដែលត្រូវការប្រើប្រាស់វា។

របាយការណ៍ហិរញ្ញវត្ថុគឺជាទម្រង់ហិរញ្ញវត្ថុដែលបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ និងប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន។ របាយការណ៍ហិរញ្ញវត្ថុគឺ សិក្សាអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងចលនាលំហូរសាច់ប្រាក់របស់អង្គភាពដែលមានប្រយោជន៍សម្រាប់ប្រើប្រាស់ និងសម្រាប់សម្រេចចិត្តក្នុងផ្នែកសេដ្ឋកិច្ច។[1] របាយការណ៍នេះក៏បង្ហាញផងដែរអំពីលទ្ធផលនៃការគ្រប់គ្រងក៏ដូចជាការចាត់ចែងធនធានរបស់អ្នកគ្រប់គ្រង។

ដើម្បីសម្រេចនូវគោលបំណងរបាយការណ៍ហិរញ្ញវត្ថុត្រូវផ្តល់ព័ត៌មានដូចខាងក្រោមៈ

- ទ្រព្យសកម្ម
- ទ្រព្យអកម្ម
- មូលនិធិម្ចាស់មូលធន
- ចំណូល ចំណាយ រួមបញ្ចូលទាំងចំណេញខាតរបស់ក្រុមហ៊ុន
- និងលំហូរសាច់ប្រាក់។

ព័ត៌មានទាំងអស់នេះភ្ជាប់មកជាមួយនឹងព័ត៌មានដទៃទៀតនៅក្នុងកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ និងជួយឲ្យអ្នកប្រើប្រាស់ធ្វើការប៉ាន់ស្មានពីចលនាសាច់ប្រាក់របស់ក្រុមហ៊ុនក្នុងពេលអនាគត ជាពិសេសការកំណត់អំពីពេលវេលា និងភាពច្បាស់លាស់ក្នុងការបង្កើតសាច់ប្រាក់ និងសាច់ប្រាក់សមមូល។[2]

[1] https://www.wikiaaccounting.com/five-types-of-financial-statements-ifrs/ (ចូលមើលថ្ងៃទី ១៣ ឧសភា ២០២១)

[2] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១ (CIAS1) ទំព័រ១៤

### ១.១.២. ទម្រង់របាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ គឺជាទម្រង់នៃការបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ និងការប្រើប្រាស់ហិរញ្ញវត្ថុរបស់អង្គភាពមួយៗ របាយការណ៍នេះចែកចេញជាបួនប្រភេទរួមមានៈ

- របាយការណ៍លទ្ធផល (Income Statement)
- របាយការណ៍ប្រាក់ចំណេញរក្សាទុក (Retained Earnings Statement)
- តារាងតុល្យការ (Statement of Financial Position)
- របាយការណ៍លំហូរសាច់ប្រាក់ (Statement of Cash Flow)

#### ១.១.២.១. របាយការណ៍លទ្ធផល ( Income Statement )

របាយការណ៍លទ្ធផល គឺជារបាយការណ៍ហិរញ្ញវត្ថុដ៏សំខាន់មួយដែលបង្ហាញអំពីប្រាក់ចំណេញ ឬខាតបង់ ឬបង្ហាញអំពីលទ្ធផលហិរញ្ញវត្ថុនៃប្រតិបត្តិការអាជីវកម្មនៅកំឡុងពេលជាក់លាក់ណាមួយ។[3] ចំណេញ ឬក៏ខាតត្រូវបានគណនាដោយយកចំណូលទាំងអស់ ដកជាមួយនិងចំណាយទាំងអស់ដែលបានមកពីប្រតិបត្តិការ។

តារាងទី១៖ របាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន xxx

Company Name
Income Statement
For the Years ended December 31, 20XX

| | | |
|---|---|---|
| Revenue | | |
| Service revenue | | xxx |
| Expenses | | |
| Salaries and wages expense | xxx | |
| Rent expense | xxx | |
| Advertising expense | xxx | |
| Utilities expense | xxx | |
| Total expense | | xxx |
| Net Income | | xxx |

[3] Weygandt, Kimmel & Kieso. 2014. Financial Accounting. 9th Edition. Page 22

**១.១.២.២. របាយការណ៍ប្រាក់ចំណេញរក្សាទុក** ( Retained Earnings Statement )

របាយការណ៍ប្រាក់ចំណេញរក្សាទុក គឺជាចំនួនប្រាក់ចំណូលសុទ្ធដែលនៅសល់សម្រាប់អាជីវកម្ម បន្ទាប់ពីបានទូទាត់ភាគលាភទៅឲ្យម្ចាស់ភាគហ៊ុនរបស់ខ្លួន។ របាយការណ៍ប្រាក់ចំណេញរក្សាទុកនេះ គឺមានសារៈសំខាន់ណាស់សម្រាប់វិនិយោគិន និងម្ចាស់ភាគហ៊ុន ព្រោះវិនិយោគិនសង្ឃឹមថាភាពជាម្ចាស់ភាគហ៊ុន នឹងផ្តល់ឲ្យពួកគេនូវភាគលាភ ឬការឡើងនូវតម្លៃភាគហ៊ុន។[4]

តារាងទី២៖ របាយការណ៍ប្រាក់ចំណេញរក្សាទុករបស់ក្រុមហ៊ុន xxx

Company Name
Retained Earnings Statement
For the Years ended December 31, 20XX

| | | |
|---|---|---|
| Retained earnings, Jan.1 | | xxx |
| Net income | | xxx |
| Total | | xxx |
| Dividend Deducted | xxx | |
| Retained earnings, Dec.31 | | xxx |

**១.១.២.៣. តារាងតុល្យការ** ( Statement of Financial Position )

តារាងតុល្យការ គឺជារបាយការណ៍មួយដែលបង្ហាញពី តម្លៃគណនារបស់ក្រុមហ៊ុននៅក្នុងកាលបរិច្ឆេទជាក់លាក់ណាមួយ ។ តារាងតុល្យការរាយការណ៍ព័ត៌មានទូទៅអំពី ទ្រព្យសកម្ម (Assets) បំណុល (Liabilities) និងទុនរបស់ម្ចាស់ទ្រព្យ (Stockholder Equity) ។[5] តារាងនេះធ្វើឲ្យឃើញពីភាពខ្លាំង និងខ្សោយរបស់ក្រុមហ៊ុនយ៉ាងជាក់ច្បាស់។

[4] Weygandt, Kimmel & Kieso. 2012. Accounting Principle. 10th Edition. Page 23

[5] https://www.investopedia.com/terms/b/balancesheet.asp (ចូលមើលថ្ងៃទី ១៥ ឧសភា ២០២១)

តារាងទី៣៖ តារាងតុល្យការរបស់ក្រុមហ៊ុន xxx

Company Name
Statement of Financial Position
December 31, 20xx

| Assets | | |
|---|---|---|
| Equipment | | xxx |
| Supplies | | xxx |
| Account receivable | | xxx |
| Cash | | xxx |
| Total assets | | xxx |
| Shareholders´Equity and Liabilities | | |
| Equity | | |
| Share capital-ordinary | | xxx |
| Retained earnings | | |
| Liabilities | xxx | |
| Accounts payable | xxx | xxx |
| Total equity and liabilities | | xxx |

**១.១.២.៤. របាយការណ៍ចលនាលំហូរសាច់ប្រាក់** (Statement of Cash Flows)

របាយការណ៍ចលនាលំហូរសាច់ប្រាក់ គឺជារបាយការណ៍ហិរញ្ញវត្ថុមួយដែលសង្ខេបពីចំនួនសាច់ប្រាក់ និងសមមូលចលនាសាច់ប្រាក់ដែលចេញ និងចូលក្រុមហ៊ុន។ របាយការណ៍នេះបង្ហាញពីប្រភពនៃលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនហើយ វាគឺជួយឲ្យវិនិយោគិនដឹងពីដំណើរការអាជីវកម្ម ថាតើក្រុមហ៊ុនបានសាច់ប្រាក់មកពីប្រភពណា និងបានចំណាយសាច់ប្រាក់ទាំងនោះទៅលើអ្វីខ្លះ?[6] របាយការណ៍ចលនាលំហូរសាច់ប្រាក់នេះ បង្ហាញឲ្យឃើញអំពី

[6] Peter M. Bergevin. 2001. Financial Statement Analysis. International Edition. Page 75

ចលនាលំហូរសាច់ប្រាក់ចូល និងលំហូរសាច់ប្រាក់ចេញតាមរយៈសកម្មភាពប្រតិបត្តិការ សកម្មភាពវិនិយោគ និងសកម្មភាពហិរញ្ញវត្ថុ។[7]

តារាងទី៤៖ របាយការណ៍ចលនាលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន xxx

Company Name
Statement of Cash Flows
For the Years ended, 20XX

| | | |
|---|---|---|
| Cash flows from operating activities | | |
| Cash receipts from revenue | | xxx |
| Cash payments for expenses | | xxx |
| Net cash provided by operating activities | | xxx |
| Cash flows from investing activities | | |
| Purchase of equipment | | xxx |
| Cash flow from financing activities | | |
| Sale of common stock | xxx | |
| Payment of cash dividends | xxx | xxx |
| Net increase in cash | | xxx |
| Cash at beginning of the period | | xxx |
| Cash at the end of the period | | xxx |

## ១.២. ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺជាដំណើរការនៃការវាយតម្លៃទៅលើអាជីវកម្ម គម្រោង ថវិកា និងរបាយការណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលទាក់ទងនឹងប្រតិបត្តិការដើម្បីកំណត់អំពីការអនុវត្តជាក់ស្តែងរបស់ពួកគេ និងភាពសមរម្យដែលអាចទទួលយកបាន។ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺប្រើដើម្បីវិភាគអំពីស្ថានភាពរបស់អង្គភាព

[7] Weygandt, Kimmel & Kieso. 2015. Financial Accounting. 3th IFRS Edition. Page 646

សមត្ថភាពរបស់ក្រុមហ៊ុនក្នុងការសងបំណុលរយៈពេលវែង ប្រសិទ្ធភាពនៃការបម្លែងទ្រព្យសកម្មជាសាច់ប្រាក់បានឆាប់រហ័ស និងលទ្ធភាពស្វែងរកប្រាក់ចំណេញ ដើម្បីធានាពីការវិនិយោគរូបិយវត្ថុ។[8]

## ១.៣. គោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ

ការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺជាការវិភាគអំពីព័ត៌មានហិរញ្ញវត្ថុដែលរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុពីគ្រាមុន និងគ្រាបច្ចុប្បន្នដើម្បីដឹងពីស្ថានភាពហិរញ្ញវត្ថុរបស់សហគ្រាសមួយថាតើមានដំណើរការអាជីវកម្មល្អ ឬក៏មិនល្អ ទាំងផ្នែកគ្រប់គ្រងប្រតិបត្តិការអាជីវកម្ម និងផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ។ ការវិភាគរបាយការណ៍ហិរញ្ញវត្ថុជាការវិភាគអំពីសេដ្ឋកិច្ច ការកំណត់គោលការណ៍ហិរញ្ញវត្ថុ ការកសាងនូវផែនការរយៈពេលវែងសម្រាប់សកម្មភាពអាជីវកម្ម និងការកំណត់នូវអត្តសញ្ញាណរបស់ផែនការ ឬក៏គម្រោងនៃការវិនិយោគរបស់ក្រុមហ៊ុន។ ម្យ៉ាងទៀតនោះការវិភាគរបាយការណ៍ហិរញ្ញវត្ថុនេះផងដែរអាចជួយឲ្យក្រុមហ៊ុន ឬសហគ្រាសដឹងនូវកំហុសឆ្គងដែលបានកើតឡើងនៅក្នុងសកម្មភាពអាជីវកម្មរបស់ពួកគេ ព្រមទាំងធ្វើការកែលម្អនូវចំណុចខុសឆ្គងទាំងនោះឲ្យមានភាពប្រសើរឡើងវិញដើម្បីទទួលបានជោគជ័យ។

គោលបំណងនៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុ គឺដើម្បីវិភាគអំពីអង្គភាពអាជីវកម្មរបស់សហគ្រាស និងក្រុមហ៊ុនដើម្បីស្វែងយល់អំពីលទ្ធភាពនៃការទូទាត់បំណុលរបស់ក្រុមហ៊ុន ប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ និងប្រាក់ចំណេញដែលក្រុមហ៊ុន ឬសហគ្រាសរកបានពីការវិនិយោគ។

## ១.៤. ឧបករណ៍វិភាគរបាយការណ៍ហិរញ្ញវត្ថុ

ឧបករណ៍នៃការវិភាគរបាយការណ៍ហិរញ្ញវត្ថុមានបីគឺៈ ការវិភាគតាមទំហំរួម ឬជួរឈរ(Vertical Analysis) ការវិភាគតាមជួរដេក ឬឆ្នាំគោលរួម (Horizontal Analysis) និងការវិភាគតាមអនុបាត (Ratio Analysis)។[9]

### ១.៤.១.ការវិភាគតាមជួរឈរ (Vertical Analysis)

ការវិភាគតាមទំហំរួម ឬការវិភាគតាមជួរឈរ គឺជាការវិភាគរបាយការណ៍ហិរញ្ញវត្ថុដោយយកធាតុនិមួយៗធៀបសមាមាត្រជាភាគរយនឹងគណនីរួមដែលស្ថិតនៅក្នុងរបាយការណ៍លទ្ធផល និងតារាងតុល្យការ។ រាល់ធាតុទាំងអស់ដែលមាននៅក្នុងរបាយការណ៍លទ្ធផលគឺត្រូវធៀបសមាមាត្រជាភាគរយនឹងចំណូលពីការលក់សុទ្ធ (Net Sales) ហើយចំណែករាល់ធាតុទាំងអស់ដែលមាននៅក្នុងតារាងតុល្យការគឺត្រូវធៀបសមាមាត្រជាភាគរយជាមួយនឹងទ្រព្យសកម្មសរុប (Total Assets) ឬក៏ធៀបជាមួយនឹងបំណុលសរុប (Total Liabilities) និងមូលធនសរុប (Total

---

8 John J. Wild, Leopold A. Bernstein, K.R.Subramanyam. 2009. Financial Statement Analysis. 10th Edition. Page 8

9 Weygandt. Kimmel & Kieso,2014. Financial Accounting. 9th Edition. Page 714

Equity)។ ការវិភាគតាមទំហំរួមនេះ គឺដើម្បីស្វែងយល់អំពីការផ្លាស់ប្តូរផលធៀបនៃគណនីរួមជាមួយនឹងគណនីដទៃទៀតដែលជាធាតុនៃគណនីរួម ឬបង្ហាញពីទំនាក់ទំនងរវាងធាតុនិមួយៗទៅនឹងគណនីរួម។ ការវិភាគតាមជួរឈរ គឺមានសារៈសំខាន់ណាស់ក្នុងការប្រៀបធៀបស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមួយទៅនឹងក្រុមហ៊ុនមួយផ្សេងទៀត។

$$\text{Percentage of Item (In Balance Sheet)} = \frac{\text{Each Items on Balance Sheet}}{\text{Total Asset Or Total Liabilities\&Equity}} \times 100$$

$$\text{Percentage of Item (In Income Statement)} = \frac{\text{Each Items on Income Statement}}{\text{Net Sales}} \times 100$$

### ១.៤.២. ការវិភាគតាមជួរដេក (Horizontal Analysis)

ការវិភាគតាមនិន្នាការ ឬការវិភាគតាមជួរដេក គឺត្រូវបានប្រើប្រាស់ដើម្បីធ្វើការវិភាគរបាយការណ៍ហិរញ្ញវត្ថុដោយធ្វើការប្រៀបធៀបព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុក្នុងកំឡុងគ្រាមួយ ជាមួយនឹងព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុក្នុងកំឡុងគ្រាមួយផ្សេងទៀត។ វាត្រូវបានប្រើដើម្បីប្រៀបធៀបតម្លៃនៃឆ្នាំបច្ចុប្បន្នជាមួយនឹងឆ្នាំគោល។ គោលបំណងរបស់វាគឺដើម្បីដឹងអំពីការកើនឡើង ឬថយចុះនៃតម្លៃនៅក្នុងឆ្នាំណាមួយដែលបានយកមកប្រៀបធៀបជាមួយនឹងឆ្នាំគោល។[10]

$$\text{Horizontal Analysis (\%)} = \frac{\text{Amount in Comparison Year} - \text{Amount in Base Year}}{\text{Amount in Base Year}} \times 100$$

### ១.៤.៣. ការវិភាគតាមអនុបាត (Ratio Analysis)

ការវិភាគតាមអនុបាតគឺបង្ហាញធាតុដែលយើងយកមកគណនាដែលជាទិន្នន័យនៃរបាយការណ៍ហិរញ្ញវត្ថុ។ អនុបាតគឺបង្ហាញអំពីទំនាក់ទំនងគណិតវិទ្យារវាងបរិមាណមួយ ជាមួយនឹងបរិមាណមួយទៀត។ ទំនាក់ទំនងនេះវាបង្ហាញក្នុងលក្ខខណ្ឌជាភាគរយ អត្រា ឬជាសមាមាត្រ។ ឧទាហរណ៍: Nick, Inc មានទ្រព្យសកម្មរយៈពេលខ្លីចំនួន $11,297 លាន និងបំណុលរយៈពេលខ្លីចំនួន $3,958 លាន យើងអាចរកឃើញនូវទំនាក់ទំនងរវាងធាតុទាំងពីរនេះដោយយកទ្រព្យសកម្មរយៈពេលខ្លី ធៀបជាមួយនឹងបំណុលរយៈពេលខ្លី។[11]

$$\frac{\text{Ca}}{\text{Cl}} = \frac{១១,២៩៧}{៣,៩៥៨} = ២,៨៥$$

[10] Weygandt, Kimmel & Kieso. 2015. Financial Accounting. 3th IFRS Edition. Page 713

[11] Weygandt, Kimmel & Kieso. 2014. Financial Accounting. 9th Edition. Page 720

❖ លទ្ធផលបង្ហាញថា៖

- Percentage: ទ្រព្យសកម្មរយៈពេលខ្លីមាន ២៨៥% នៃបំណុលរយៈពេលខ្លី
- Rate : ទ្រព្យសកម្មរយៈពេលខ្លីមាន ២,៨៥ ដងនៃបំណុលរយៈពេលខ្លី
- Proportion: ផលធៀបរវាងទ្រព្យសកម្មរយៈពេលខ្លីជាមួយនឹងបំណុលរយៈពេលខ្លីគឺ ២,៨៥

**១.៤.៣.១.អនុបាតសន្ទនីយភាព (Liquidity Ratio)**

អនុបាតសន្ទនីយភាព ត្រូវបានគេប្រើប្រាស់សម្រាប់វាស់វែងនូវសមត្ថភាពទូទាត់បំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុនដែលមានកាតព្វកិច្ចសងបំណុលតាមកាលកំណត់ដូចដែលមានក្នុងកាលបរិច្ឆេទ និងដើម្បីដឹងអំពីតម្រូវការសាច់ប្រាក់ដែលក្រុមហ៊ុនត្រូវការបន្ទាន់ក្នុងកាលៈទេសៈណាមួយ។ ម្ចាស់បំណុលរយៈពេលខ្លីដូចជា ធនាគារ និងអ្នកផ្គត់ផ្គង់គឺចាប់អារម្មណ៍ទៅលើអនុបាតរយៈពេលខ្លីនេះ។

**ក.អនុបាតចរន្ត (Current Ratio)**

អនុបាតចរន្ត គឺជាអនុបាតដែលត្រូវបានប្រើយ៉ាងទូលំទូលាយសម្រាប់វាស់វែងពីសាច់ប្រាក់របស់ក្រុមហ៊ុន និងសមត្ថភាពទូទាត់បំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុន។ អនុបាតនេះត្រូវបានគណនាដោយយក ទ្រព្យសកម្មរយៈពេលខ្លី ធៀបជាមួយបំណុលរយៈពេលខ្លី។[12]

$$\text{Current Ratio} = \frac{\text{Current Assets}}{\text{Current Liabilities}}$$

**ខ.អនុបាតរហ័ស (Quick Ratio)**

អនុបាតរហ័ស គឺជាអនុបាតប្រើដើម្បីវាស់វែងពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការទូទាត់បំណុលរយៈពេលខ្លី ដោយមិនចាំបាច់លក់សន្និធិ ឬទទួលយកនូវហិរញ្ញប្បទានបន្ថែមពីខាងក្រៅ។ កាលណាអនុបាតនេះមានកម្រិតខ្ពស់ អង្គភាពកាន់តែមានស្ថានភាពហិរញ្ញវត្ថុល្អ ប៉ុន្តែបើវាមានកម្រិតទាបនោះអង្គភាពនឹងមានការលំបាក ឬរាំងស្ទះសាច់ប្រាក់ក្នុងការទូទាត់បំណុល។[13]

$$\text{Quick Ratio} = \frac{\text{Current Assets - Inventory}}{\text{Current Liabilities}}$$

[12] Ross,Westerfield, Jordan. 2008. Fundamentals of Corporate Finance. 8th Edition. Page 57

[13] Berk J., DeMarzo P. and Harford J. Fundamentals of Corporate Finance. 2nd Edition. Page 32

### គ.អនុបាតបង្វិលជុំនៃឥណទេយ្យ ( Accounts Receivable Turnover)

អនុបាតបង្វិលជុំនៃឥណទេយ្យ គឺប្រើប្រាស់សម្រាប់វាស់វែងអំពីភាពដែលក្រុមហ៊ុនងាយបម្លែងទ្រព្យសកម្មទៅជាសាច់ប្រាក់ ។[14] អនុបាតនេះវាស់វែងចំនួនដងជាមធ្យមដែលក្រុមហ៊ុនអាចប្រមូលប្រាក់នៅកំឡុងគ្រាណាមួយ ហើយវាត្រូវបានគណនាដោយយក ចំណូលពីការលក់សុទ្ធ ធ្វើការធៀបជាមួយនឹងឥណទេយ្យ។

$$\text{Receivable Turnover} = \frac{\text{Net Credit Sales}}{\text{Net Account Receivable}}$$

- **អនុបាតចំនួនថ្ងៃដែលឥណទេយ្យសង (Days´ Sale in Receivable)**

អនុបាតចំនួនថ្ងៃដែលឥណទេយ្យសង គឺជាអនុបាតដែលបង្ហាញពីចំនួនថ្ងៃជាមធ្យមដែលត្រូវបានចំណាយពេលសម្រាប់ក្រុមហ៊ុនមួយក្នុងការប្រមូលប្រាក់ជំពាក់ពីអតិថិជនបន្ទាប់ពីការលក់បានកើតឡើង។ អនុបាតនេះគឺត្រូវបានវាស់វែងពីកម្រិតដែលអតិថិជនសងប្រាក់លឿន ឬយឺត ព្រមទាំងប្រសិទ្ធភាពនៃការគ្រប់គ្រងឥណទេយ្យរបស់ក្រុមហ៊ុនមួយ។[15]

$$\text{Days' Sales in Receivable} = \frac{\text{365 days}}{\text{Receivables Turnover}}$$

### ឃ.អនុបាតបង្វិលជុំនៃសន្និធិ (Inventory Turnover)

គេប្រើប្រាស់អនុបាតបង្វិលជុំនៃសន្និធិ ដើម្បីធ្វើការវាស់វែងចំនួនដងជាមធ្យមភាគទៅលើសន្និធិដែលលក់បាន។ វាវាស់វែងអំពីសន្ទនីយភាពនៃសន្និធិហើយ អនុបាតនេះត្រូវបានគេគណនាដោយ យកចំណាយថ្លៃដើម ទៅធៀបជាមួយនឹងសន្និធិ។[16]

$$\text{Inventory Turnover} = \frac{\text{Cost of Goods Sold}}{\text{Inventory}}$$

[14] Weygandt, Kimmel & Kieso. 2015. Financial Accounting. 3th IFRS Edition. Page 721

[15] https://www.investopedia.com/terms/r/receivableturnoverratio.asp (ចូលមើលថ្ងៃទី ២១ ឧសភា ២០២១)

[16] Weygandt, Kimmel & Kieso. 2014. Financial Accounting. 9th Edition. Page 724

❖ **អនុបាតចំនួនថ្ងៃនៃការលក់សន្និធិ (Day's Sale in Inventory)**

អនុបាតចំនួនថ្ងៃនៃការលក់សន្និធិ គឺជាអនុបាតដែលបង្ហាញអំពីចំនួនថ្ងៃជាមធ្យមដែលត្រូវបានចំណាយដោយក្រុមហ៊ុនមួយក្នុងការលក់ចេញនូវសន្និធិ។ អនុបាតនេះជាមូលដ្ឋានមួយសម្រាប់អ្នកគ្រប់គ្រងប្រើប្រាស់ដើម្បីកំណត់នូវប្រសិទ្ធភាពនៃការលក់ ហើយប្រសិនបើតួលេខនៃអនុបាតនេះខ្ពស់ មានន័យថាអង្គភាពមួយនោះគ្រប់គ្រងសន្និធិមិនបានល្អ ឬអាចមានសន្និធិដែលពិបាកលក់ចេញ។[17]

$$\text{Days' Sales in Inventory} = \frac{\text{365 days}}{\text{Inventory Turnover}}$$

**១.៤.៣.២. អនុបាតនៃលទ្ធភាពទូទាត់បំណុល (Solvency Ratio)**

អនុបាតនៃលទ្ធភាពទូទាត់បំណុល គឺប្រើប្រាស់សម្រាប់វាស់វែងនូវសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការទូទាត់បំណុលរយៈពេលវែង ដែលក្រុមហ៊ុននឹងត្រូវគោរពតាមកាតព្វកិច្ចសងបំណុលតាមពេលវេលាកំណត់សង។

**ក. អនុបាតបំណុលធៀបជាមួយទ្រព្យសកម្ម (Debt To Assets Ratio)**

អនុបាតបំណុលធៀបជាមួយទ្រព្យសកម្ម គឺប្រើប្រាស់សម្រាប់វាស់វែងទ្រព្យសកម្មសរុបដែលម្ចាស់បំណុលផ្តល់ឲ្យ។ យើងគណនាដោយយកបំណុលសរុប ធៀបជាមួយនឹងទ្រព្យសកម្មសរុប។ វាបង្ហាញអំពីសមត្ថភាពរបស់ក្រុមហ៊ុនដើម្បីទប់ទល់ជាមួយការខាតបង់ ដោយគ្មានការបន្ថយបន្ថយនូវការប្រាក់ពីសំណាក់ម្ចាស់បំណុល។ នៅពេលដែលភាគរយខ្ពស់នៃបំណុល ធៀបជាមួយទ្រព្យសកម្ម នោះវាបង្ហាញថាក្រុមហ៊ុនមានហានិភ័យខ្ពស់ ដែលមិនអាចធ្វើឲ្យការទូទាត់បំណុលសងបានទៅតាមកាលបរិច្ឆេទកំណត់បាន។[18]

$$\text{Debt to Assets Ratio} = \frac{\text{Total Liabilities}}{\text{Total Assets}}$$

**ខ. អនុបាតបំណុលធៀបនឹងមូលធន (Debt to Equity Ratio)**

អនុបាតបំណុលធៀបនឹងមូលធន គឺជាអនុបាតដែលវាស់វែងអំពីភាគរយនៃបំណុលធៀបទៅនឹងមូលធនរបស់ក្រុមហ៊ុន ដើម្បីដឹងពីលទ្ធភាពសងត្រលប់របស់មូលធន។ អង្គភាពដែលមានបំណុលធៀបជាមួយនឹងមូលធនខ្ពស់ គឺមានហានិភ័យខ្លាំងប្រសិនបើមានវិបត្តិសេដ្ឋកិច្ច ទោះជាចំណូលរបស់ក្រុមហ៊ុនធ្លាក់ចុះក៏ដោយ ក៏ក្រុមហ៊ុន

[17] https://www.investopedia.com/terms/d/days-sales-inventory-dsi.asp (ចូលមើលថ្ងៃទី ២១ ឧសភា ២០២១)

[18] Weygandt, Kimmel & Kieso. 2014. Financial Accounting. 9th Edition. Page 729

នៅតែមានកាតព្វកិច្ចសងការប្រាក់ និងប្រាក់ដើមដែលជំពាក់។ ចំណែកឯម្ចាស់ភាគហ៊ុនវិញ ក្រុមហ៊ុនមិនមានកាតព្វកិច្ចសងប្រាក់វិនិយោគវិញទេឡើយ ហើយការបែងចែកភាគលាភអាចនឹងត្រូវបានពន្យា រហូតដល់ពេលដែលប្រាក់ចំណេញក្រុមហ៊ុនមានឡើងវិញ។[19]

$$\text{Debt to Equity Ratio} = \frac{\text{Total Liabilities}}{\text{Total Equity}}$$

### គ. មេគុណមូលធន (Equity Multiplier)

មេគុណមូលធន គឺជាសូចនាករហានិភ័យដែលវាស់វែងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនដែលជាហិរញ្ញប្បទានរបស់ម្ចាស់ភាគហ៊ុន។ គេគណនាដោយបែងចែកទ្រព្យសកម្មសរុបជាមួយនឹងភាគហ៊ុនម្ចាស់ទ្រព្យសរុប។[20]វាបង្ហាញឲ្យឃើញអំពីទ្រព្យសកម្មមានប៉ុន្មានដុល្លារក្នុងមូលធនមួយដុល្លារ។

$$\text{Equity Multiplier} = \frac{\text{Total Assets}}{\text{Total Equity}}$$

### ឃ.អនុបាតចំនួនដងនៃការចំណាយការប្រាក់ (Times Interest Earned)

អនុបាតចំនួនដងនៃការចំណាយការប្រាក់ គឺប្រើសម្រាប់វាស់ពីលទ្ធភាពដែលប្រាក់ចំណេញពីប្រតិបត្តិការរបស់ក្រុមហ៊ុនអាចធ្លាក់ចុះ មុនពេលនឹងក្រុមហ៊ុនមិនមានលទ្ធភាពសងការប្រាក់។ ការមិនសងការប្រាក់តាមកាលកំណត់ អាចនាំឱ្យមានការប្ដឹងពីម្ចាស់បំណុល ហើយអាចឈានទៅដល់ការក្ស័យធនផងដែរ។[21] អនុបាតនេះត្រូវបានគណនាដោយចែកប្រាក់ចំណេញ និងពន្ធមុនចំណាយការប្រាក់ ជាមួយនឹងចំណាយការប្រាក់។

$$\text{Time Interest Earned Ratio} = \frac{\text{Earnings Before Interest and Tax}}{\text{Interest}}$$

[19] Belverd E. Needles and Marian Powersm. 2007. Financial Accounting. Page 252

[20] https://www.investopedia.com/terms/e/equitymultiplier.asp (ចូលមើលថ្ងៃទី២០ ឧសភា ២០២១)

[21] Eugene F. Brigham, Michael C. Ehrhardt. 2002. Financial Management. Page 252

**១.៤.៣.៣.អនុបាតនៃលទ្ធភាពស្វែងរកប្រាក់ចំណេញ (Profitability Ratio)**

អនុបាតលទ្ធភាពស្វែងរកប្រាក់ចំណេញ គឺត្រូវបានប្រើប្រាស់សម្រាប់វាស់វែងប្រាក់ចំណេញ ឬប្រតិបត្តិការដែលក្រុមហ៊ុនលក់បានក្នុងកំឡុងគ្រា។ ចំណេញ ឬខាត វាគឺជះឥទ្ធិពលទៅដល់សមត្ថភាពរបស់ក្រុមហ៊ុនក្នុងការសងបំណុល។

**ក.អនុបាតប្រាក់ចំណេញសុទ្ធ (Profit Margin)**

អនុបាតប្រាក់ចំណេញសុទ្ធ ត្រូវបានប្រើប្រាស់សម្រាប់វាស់វែងនូវលទ្ធភាពស្វែងរកប្រាក់ចំណេញសុទ្ធដែលក្រុមហ៊ុនទទួលបានពីការលក់ ។ អនុបាតនេះ គឺជាផលធៀបរវាងប្រាក់ចំណេញសុទ្ធ ជាមួយនឹងប្រាក់ចំណូលពីការលក់សុទ្ធរបស់ក្រុមហ៊ុន។ អនុបាតនេះវាស់វែងពីលទ្ធភាពស្វែងរកប្រាក់ចំណេញពិតដែលក្រុមហ៊ុនទទួលបានរៀងរាល់មួយដុល្លារនៃប្រាក់ចំណេញសុទ្ធ។ ជាទូទៅអ្នកវិនិយោគទុន និងម្ចាស់ភាគហ៊ុនគឺតែងតែមានការចាប់អារម្មណ៍ និងធ្វើការវាយតម្លៃពីប្រាក់ចំណេញរបស់ក្រុមហ៊ុន។ បើអនុបាតនេះកាន់តែធំ គឺកាន់តែល្អ ដោយសារវាបានបង្ហាញថាក្រុមហ៊ុនទទួលបានប្រាក់ចំណេញកាន់តែច្រើនពីប្រតិបត្តិការរបស់ខ្លួន។

$$\text{Profit Margin} = \frac{\text{Net Income}}{\text{Net Sales}}$$

**ខ.អនុបាតបង្វិលជុំនៃទ្រព្យសកម្ម (Asset Turnover)**

អនុបាតបង្វិលជុំនៃទ្រព្យសកម្ម គឺត្រូវបានប្រើប្រាស់សម្រាប់វាស់វែងពីវិធីសាស្ត្រដែលក្រុមហ៊ុនប្រើប្រាស់ទ្រព្យសកម្មរបស់ខ្លួនឲ្យមានប្រសិទ្ធភាពដើម្បីទាញរកប្រាក់ចំណេញពីសកម្មភាពអាជីវកម្ម ។ អនុបាតនេះ គឺជាផលធៀបរវាងប្រាក់ចំណូលដែលបានពីការលក់សុទ្ធ និងចំនួនទ្រព្យសកម្មសរុប។[22] វាបង្ហាញអំពីប្រាក់ចំណូលដុល្លាដែលទទួលបានពីការវិនិយោគរៀងរាល់មួយដុល្លា ទៅលើទ្រព្យសកម្ម។ ចំពោះក្រុមហ៊ុនដែលមាន Assets Turnover ខ្ពស់មានន័យថា ក្រុមហ៊ុននោះបានប្រើប្រាស់ទ្រព្យសកម្មបានល្អជាងក្រុមហ៊ុនដែលមាន Total Assets Turnover ទាប។

$$\text{Total Asset Turnover} = \frac{\text{Net Sales}}{\text{Total Assets}}$$

[22] Ross,Westerfield, Jordan. 2008. Fundamentals of Corporate Finance. 8th Edition. Page 63

### គ.អនុបាតប្រាក់ចំណេញពីទ្រព្យសកម្ម (Return on Assets)

អនុបាតប្រាក់ចំណេញពីទ្រព្យសកម្ម គឺប្រើសម្រាប់វាស់វែងអំពីលទ្ធភាពស្វែងរកប្រាក់ចំណេញដែលទទួលបានពីទ្រព្យសកម្ម។ អនុបាតនេះ គឺជាផលធៀបរវាងប្រាក់ចំណេញសុទ្ធ ជាមួយនឹងទ្រព្យសកម្មសរុប។[23] ប្រសិនបើតម្លៃនៃអនុបាតកាន់តែធំ គឺកាន់តែល្អប្រសើរ ព្រោះវាបង្ហាញពីប្រសិទ្ធភាពនៃការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុនក្នុងការបង្កើតប្រាក់ចំណេញកាន់តែប្រសើរ។ ប៉ុន្តែប្រសិនបើតម្លៃនៃអនុបាតនេះកាន់តែទាប នោះគឺមានន័យថាការប្រើប្រាស់ទ្រព្យសកម្មរបស់ក្រុមហ៊ុនគ្មានប្រសិទ្ធភាពក្នុងការបង្កើតប្រាក់ចំណេញទេ។[24]

$$\text{Return on Assets}=\frac{\text{Net Income}}{\text{Total Assets}}$$

### ឃ.អនុបាតប្រាក់ចំណេញធៀបនឹងមូលធន (Return on Equity)

អនុបាតប្រាក់ចំណេញធៀបនឹងមូលធន ប្រើប្រាស់សម្រាប់វាស់វែងអំពីលទ្ធភាពស្វែងរកប្រាក់ចំណេញនៃការវិនិយោគរបស់ម្ចាស់ភាគហ៊ុន។ វាបង្ហាញឲ្យឃើញថាតើក្រុមហ៊ុនទទួលបានប្រាក់ចំណេញប៉ុន្មានពីការប្រើប្រាស់មូលធនមួយដុល្លាសម្រាប់វិនិយោគ។ ប្រសិនបើលទ្ធផលនៃអនុបាតកាន់តែធំ គឺកាន់តែល្អមានន័យថាក្រុមហ៊ុនបានប្រើប្រាស់មូលធនក្នុងការបង្កើតប្រាក់ចំណេញមានប្រសិទ្ធភាពខ្ពស់ប៉ុន្តែប្រសិនបើអនុបាតកាន់តែតូចនោះបញ្ជាក់ថាការប្រើប្រាស់មូលធនរបស់ក្រុមហ៊ុនពុំមានប្រសិទ្ធភាពនោះទេ។

$$\text{Return on Equity}=\frac{\text{Net Income}}{\text{Total Equity}}$$

### ង.អនុបាតប្រាក់ចំណេញក្នុងមួយហ៊ុន (Earnings Per Share) EPS

អនុបាតប្រាក់ចំណេញក្នុងមួយហ៊ុនត្រូវបានគេយកមកប្រើប្រាស់ សម្រាប់វាស់វែងអំពីប្រាក់ចំណេញសុទ្ធក្នុងមួយភាគហ៊ុនរបស់ក្រុមហ៊ុន។ យើងគណនាដោយយកប្រាក់ចំណេញសុទ្ធពីការលក់ហ៊ុន ធៀបជាមួយនឹងចំនួនភាគហ៊ុនទាំងអស់។

$$\text{Earnings per Share}=\frac{\text{Net Income}}{\text{Weighted Common Shares Outstanding}}$$

[23] Ross,Westerfield, Jordan. 2008. Fundamentals of Corporate Finance. 8th Edition. Page 64

[24] https://www.readyratios.com/reference/profitablility/return_on_assets.html (ចូលមើលថ្ងៃទី ២៣ ឧសភា ២០២១)

### ច.អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ (Price-Earnings Ratio)

អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ គឺប្រើសម្រាប់វាស់វែងតម្លៃទីផ្សារភាគហ៊ុននៃប្រាក់ចំណេញក្នុងមួយភាគហ៊ុនរបស់ក្រុមហ៊ុន។ អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ (PE) ឆ្លុះបញ្ចាំងឲ្យអ្នកវិនិយោគឃើញអំពីប្រាក់ចំណេញដែលក្រុមហ៊ុនអាចរកបានក្នុងពេលអនាគត។ យើងគណនាអនុបាតនេះដោយយកតម្លៃទីផ្សារភាគហ៊ុនក្នុងមួយហ៊ុន ធៀបជាមួយនឹងប្រាក់ចំណេញក្នុងមួយហ៊ុន។[25]

$$\text{Price Earnings Ratio} = \frac{\text{Market Price per Share}}{\text{Earnings per Share}}$$

[25] Weygandt, Kimmel & Kieso. 2014. Financial Accounting. 9th Edition. Page 728

# ជំពូកទី ២
# ស្ថានភាពទូទៅរបស់
# ក្រុមហ៊ុន BMW AG

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ក្រុមហ៊ុន BMW AG

ក្រុមហ៊ុន BMW AG ជាក្រុមហ៊ុនផលិតរថយន្តមួយដែលល្បីឈ្មោះនៅលើពិភពលោក ដែលមានទីស្នាក់ការកណ្តាលនៅទីក្រុងម៉ូនិចប្រទេសអាឡឺម៉ង់ និងមានសាខាជាច្រើននៅជុំវិញសកលលោក។ នៅក្នុងជំពូកនេះ យើងនឹងបង្ហាញពីទិដ្ឋភាពទូទៅរបស់ក្រុមហ៊ុនមានដូចជា ប្រវត្តិក្រុមហ៊ុន ផលិតផល និងនិមិត្តសញ្ញាជាដើម។

## ២.១ប្រវត្តិរបស់ក្រុមហ៊ុន BMW

ស្ថាបនិក របស់ក្រុមហ៊ុន BMW មានឈ្មោះ Gustav Otto, Karl Rapp, Camillo Castiglioni និង Franz Josef Popp។




*រូបភាពទី ១ ៖* **Gustav Otto**

*(កើតនៅ ថ្ងៃទី ១២ ខែមករា ឆ្នាំ ១៨៨៣)*




*រូបភាពទី ២ ៖* **Karl Rapp**

*(កើតនៅ ថ្ងៃទី២៤ ខែសីហា ឆ្នាំ ១៨៨២)*




*រូបភាពទី ៣ ៖* **Franz Josef Popp**

*(កើតនៅ ថ្ងៃទី ១៤ ខែមករា ឆ្នាំ ១៨៨៦)*



*រូបភាពទី ៤ ៖* **Camillo Castiglioni**

*(កើតនៅ ថ្ងៃទី ២២ ខែតុលា ឆ្នាំ១៨៧៩)*

BMW (**Bayerische Motoren Werke**) ជាភាសាអង់គ្លេស (**Bavarian Motor Works**) **Group** ដែលជាក្រុមហ៊ុនផលិត និងលក់រថយន្តឈានមុខគេនៅលើពិភពលោក។ BMW Group គឺជាក្រុមហ៊ុនអាឡឺម៉ង់ និងជាអ្នកផលិតរថយន្ត និងម៉ូតូ។ ក្រុមហ៊ុន BMW Group ជាក្រុមហ៊ុនមេរបស់យីហោរថយន្ត BMW MINI និង Rolls Royce ។ BMW ត្រូវបានបង្កើតឡើងដោយលោក **Karl Friedrich Rapp** ក្នុងឆ្នាំ **១៩១៣** ក្រោមឈ្មោះ BFW (Bayerische Flugzeug-Werke) ។ ប៉ុន្តែដោយសារតែភាពលំបាកនៃការពង្រីកក្រុមហ៊ុន Rapp បានចាកចេញហើយក្រុមហ៊ុននេះត្រូវបានគ្រប់គ្រងដោយលោក **Franz Josef** ដែលជាអ្នកឧស្សាហកម្ម Austrian ក្នុងឆ្នាំ ១៩១៧។ BMW AG បានបង្កើតឡើង **ថ្ងៃទី ៧ ខែមីនា ឆ្នាំ ១៩១៦** ដែលជាក្រុមហ៊ុនផលិតម៉ាស៊ីនយន្តហោះ និងមានទីស្នាក់ការកណ្ដាលនៅទីក្រុង Bavarian, Munich។ រឿងដែលមិននឹកស្មានដល់ ក៏បានកើតឡើង គឺសង្គ្រាមលោកលើកទីមួយ។ បន្ទាប់ពីបញ្ចប់សង្គ្រាមលោកលើកទី ១ ក្រុមហ៊ុន BMW ក៏នៅតែបន្តដំណើរការជំនួញរបស់ខ្លួនដោយធ្វើការផលិតម៉ាស៊ីនម៉ូតូ ឧបករណ៍កសិកម្ម របស់របរប្រើប្រាស់ក្នុងផ្ទះ និងហ្វ្រាំងផ្លូវរថភ្លើង។ ជាសម្មិតិផលក្រុមហ៊ុនបានផលិតម៉ូតូដំបូងរបស់ខ្លួនគឺ BMW R 32 ក្នុងឆ្នាំ ១៩២៣។ ឱកាសមួយបានកើតឡើងនៅឆ្នាំ ១៩២៨ ក្រុមហ៊ុន BMW ក៏បានទិញបានរោងចក្រផលិតរថយន្ត Fahrzeugfabrik Eisenach ហើយ ក្រុមហ៊ុន BMW បានចាប់ផ្ដើមផលិតរថយន្តអង់គ្លេសតូចមួយដែលស្ថិតនៅក្រោមអាជ្ញាប័ណ្ណរដ្ឋាភិបាលអាឡឺម៉ង់នៅក្នុងឆ្នាំ ១៩៣២ ដែលផលិតឡើងសម្រាប់ប្រជាជនអាឡឺម៉ង់។ ប៉ុន្មានឆ្នាំក្រោយមកក៏បានផលិតរថយន្តស្ព័រសម្រាប់ប្រណាំង និងរថយន្តទំនើបៗ ទៀតផងដែរ។ រឿងមួយទៀតដែលក្រុមហ៊ុនBMW មិនអាចបំភ្លេចបាន គឺការស្លាបនាយន្តហោះនៅតែជាការយកចិត្តទុកដាក់សំខាន់បំផុត។ ជាគ្រោះម្ដងទៀត ក៏បានកើតឡើងនៅសង្គ្រាមលោកទី២ បានបំផ្លិចបំផ្លាញរោងចក្រគ្មានសល់ព្រមទាំងស្លាប់កម្មកររអស់ជាច្រើននាក់ពីការទម្លាក់គ្រាប់បែក។ [26]

បន្ទាប់ពីសង្គ្រាមលោកលើកទីពីរបានបញ្ចប់នៅឆ្នាំ ១៩៤៥ BMW បានបាត់បង់ទីតាំងផលិតកម្មរបស់ខ្លួននៅ Eisenach ក្នុងតំបន់កាន់កាប់របស់សូវៀត មានន័យថាក្រុមហ៊ុនក៏បាត់បង់ជំនាញក្នុងការផលិតរថយន្ត និងម៉ូតូផងដែរ។ ក្រោយមក BMW បន្តការប្រឹងប្រែង ងើបឡើង[27]ដោយខ្លួនឯង ហើយក៏ទទួលជោគជ័យក្នុងការផលិតម៉ូតូក្រោយពីសង្គ្រាមក្នុងទម្រង់ជា BMW R24 ក្នុងឆ្នាំ ១៩៤៨ រួចក៏បន្តពង្រីកផលិតផលរបស់ខ្លួនចាប់ពីចំណុចចាប់ផ្ដើមនេះ។ នៅឆ្នាំ ១៩៥២ ក្រុមហ៊ុន BMW បានចាប់ផ្ដើមផលិតរថយន្តឡើងវិញជាមួយនឹងរថយន្តទំនើបៗ ប៉ុន្តែ

---

[26] https://en.wikipedia.org/wiki/History_of_BMW (ចូលមើលថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២១)

[27] https://www.bmwakron.com/bmw-history-bmw-dealersip-near-me.html (ចូលមើលថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០២១)

ដោយសារនៅក្នុងឆ្នាំ ១៩៥៥ ក៏ជួបបញ្ហាវិបត្តិសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ការលក់មិនអាចផ្គត់ផ្គង់លើថ្លៃដើមផលិតកម្ម និងការអភិវឌ្ឍបាន ដូច្នេះហើយទើបគេសម្រេចចិត្តថានឹងលក់ក្រុមហ៊ុនទៅឲ្យដៃគូប្រកួតប្រជែង Daimler-Benz ប៉ុន្តែដោយមានការពេញចិត្តអាណិតស្រលាញ់ ពីលោក Dr. Herbert Quandt ទើបលោកបានជួយសង្គ្រោះក្រុមហ៊ុន BMW ឱ្យរស់រានមានជីវិតឡើងវិញ។ ចាប់ពីពេលនោះមក BMW បានផលិត BMW 700 និងរថយន្តស្ព័រទំនើបៗ ហើយបានស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ។ នៅក្នុងឆ្នាំ ១៩៨០ ក្រុមហ៊ុនបានបញ្ចេញរថយន្តទំនើបៗបន្ថែមទៀត ដែលបានធ្វើឱ្យ BMW បានវិវឌ្ឍខ្លួនទៅជាក្រុមហ៊ុនផលិតរថយន្តដែលមានកំណើនខ្ពស់បំផុតនៅក្នុងប្រទេសអាឡឺម៉ង់ និងនៅជុំវិញពិភពលោក។ BMW មានការរីកចម្រើន ពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារតែវិសាលភាពនេះហើយបានធ្វើ BMW ហ៊ានទិញយីហោមួយចំនួនជាពិសេស ទិញសិទ្ធិយីហោ Rolls Royce ពីក្រុមហ៊ុន Plc ដែលជារថយន្តទំនើប និងលំដាប់កំពូលសម្រាប់វណ្ណៈអភិជន មហាសេដ្ឋីជិះ។ ការជោគជ័យមួយនេះរឹតតែបានជំរុញកម្លាំងចិត្តឲ្យក្រុមហ៊ុននេះផលិតរថយន្តទំនើបៗ រហូតមកដល់បច្ចុប្បន្ន។

## ២.២.បេសកម្មរបស់ BMW

បេសកកម្មរបស់ BMW គឺដើម្បីក្លាយជាអ្នកផ្តល់ផលិតផលឈានមុខគេ និងសេវាកម្មលំដាប់ខ្ពស់បំផុតនៅលើពិភពលោកសម្រាប់ការធ្វើដំណើរ ។ បេសកកម្មរបស់ BMW បានបង្ហាញថារថយន្ត BMW បានឈានដល់វ័យចំណាស់ហើយលែងខ្វល់ខ្វាយលើរឿងធម្មតា ឬអ្វីដែលអាចត្រូវបានកំណត់ថាជាផលិតផលដែលពេញចិត្ត។[28]

## ២.៣.ចក្ខុវិស័យរបស់ BMW

ចក្ខុវិស័យរបស់ក្រុមហ៊ុន BMW គឺ" ដើម្បីក្លាយជាក្រុមហ៊ុនផលិតរថយន្តជោគជ័យបំផុតនៅក្នុងឧស្សាហកម្មនេះ"។ ចក្ខុវិស័យរបស់ BMW បានបង្ហាញពីសូចនាករដែលក្រុមហ៊ុនចង់កំណត់ផ្លូវរីកចម្រើនរបស់ខ្លួន។ លើសពីនេះទៅទៀតជាមួយនឹងគុណភាពនេះ BMW អាចបញ្ជាក់ពីភាពជាអ្នកដឹកនាំនិងឥទ្ធិពលរបស់ខ្លួននៅក្នុងវិស័យផលិតកម្មរថយន្ត។

## ២.៤.គុណតម្លៃរបស់ BMW

- ***ការទទួលខុសត្រូវ*** ៖ យើងធ្វើការសំរេចចិត្តជាប់លាប់ហើយប្តេជ្ញាចំពោះពួកគេផ្ទាល់។ នេះអនុញ្ញាតឲ្យយើងធ្វើការដោយសេរី និងមានប្រសិទ្ធភាពជាងមុន។

[28] https://mission-statement.com/bmw/ (ចូលមើលថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០២១)

- **ការកោតសរសើរ** ៖ យើងឆ្លុះបញ្ចាំងពីសកម្មភាពរបស់យើងគោរពគ្នាផ្តល់នូវមតិយោបល់ច្បាស់លាស់និងអបអរក្នុងការជោគជ័យ។
- **តម្លាភាព** ៖ យើងទទួលស្គាល់នូវការព្រួយបារម្ភ និងកំណត់ភាពមិនស៊ីចង្វាក់គ្នាតាមមធ្យោបាយស្ថាបនាព្រមទាំងភាពស្មោះត្រង់។
- **ការជឿទុកចិត្ត**៖យើងទុកចិត្ត និងពឹងផ្អែកលើគ្នាវាគឺពិតជាចាំបាច់ប្រសិនបើយើងត្រូវធ្វើយ៉ាងឆាប់រហ័សនិងសម្រេចគោលដៅរបស់យើង។
- **ការបើកចំហ** ៖ យើងរំភើបដោយការផ្លាស់ប្តូរ និងបើកឱកាសថ្មីដោយយើងអាចរៀនពីកំហុសរបស់យើង។[29]

## ២.៥. និមិត្តសញ្ញា




*រូបភាពទី ៥ ៖ វិវត្តន៍នៃនិមិត្តសញ្ញារបស់ក្រុមហ៊ុន BMW ពីឆ្នាំ ១៩១៧ - ២០២០*

29 https://www.comparably.com/companies/bmw/mission(ចូលមើលថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០២១)

ផ្លាកសញ្ញា BMW បង្ហាញនៅលើគម្របរថយន្តគ្រប់ម៉ាកដែលបង្ហាញពីឋានៈខ្ពស់របស់ម្ចាស់។ នេះគឺជាសញ្ញាសម្គាល់ពិសេសមួយដែលបំពេញបន្ថែមយ៉ាងល្អឥតខ្ចោះនូវពាក្យស្លោក“ ហ្វ្រេដអាមហ្វានវ៉េន” ដែលមានន័យថា“ ភាពរីករាយនៃការបើកបរ” ក្រុមហ៊ុនអាល្លឺម៉ង់រួមមានម៉ាស៊ីនយន្តហោះដូច្នេះពួកគេមានឥទ្ធិពលដោយផ្ទាល់លើនិមិត្តសញ្ញា។ កំណែដំបូងមានរង្វង់មួយដែលត្រូវបានបែងចែកជាបួនផ្នែកដូចគ្នាគឺពណ៌ខៀវនិងពណ៌សគែមខ្មៅនិងអក្សរ "BMW" ។ វាគឺជាយន្តហោះដែលប្រឆាំងនឹងមេឃពណ៌ខៀវ។ ប៉ុន្តែបន្ទាប់ពីសង្គ្រាមលោកលើកទី ១ អាល្លឺម៉ង់ត្រូវបានហាមឃាត់មិនឲ្យផលិតយន្តហោះទេ ដូច្នេះរោងចក្រនេះត្រូវបានបណ្តុះបណ្តាលឡើងវិញហើយចាប់ផ្តើមផលិតឧបករណ៍កសិកម្មនិងហ្វ្រាំងសម្រាប់រថភ្លើង។ ហើយទីបំផុតនៅឆ្នាំ ១៩២៣ គាត់មានម៉ូតូដំបូងរបស់គាត់ដែលមានឡូហ្គូ BMW ពណ៌ខៀវនិងស។[30] ដូច្នេះបានចាប់ផ្តើមយុគសម័យថ្មីនៃម៉ាក។ បន្ទាប់ពី ៥ ឆ្នាំក្រោយមកក្រុមហ៊ុនបានទិញរោងចក្រផលិតរថយន្តនៅអ៊ីសាណាចហើយបានចាប់ផ្តើមផលិតរថយន្តដំបូងរបស់ខ្លួនដែលមានឈ្មោះថា ឌីស៊ី។ នៅពាក់កណ្តាលទសវត្សឆ្នាំ ១៩៣០ BMW បានក្លាយជាក្រុមហ៊ុនឧស្សាហកម្មដ៏ធំមួយនៅទីក្រុងបាវ៉ារៀ ហើយសាជីវកម្មនេះបានក្លាយជាសម្ព័ន្ធឧស្សាហកម្មធំបំផុតនៅអឺរ៉ុប។ ហើយនិមិត្តសញ្ញារបស់វាឥឡូវនេះត្រូវបានគេចាត់ទុកថាជាសញ្ញានៃកិត្យានុភាពនិងឋានៈខ្ពង់ខ្ពស់។




***រូបភាពទី ៦ ៖ BMW AG 's subsidiaries***

[30] https://logos-world.net/bmw-logo/?__cf_chl_jschl_tk__=pmd_1c9bce7b116ddb59f19bef777892b9215f0a724f-1628178560-0-gqNtZGzNAg2jcnBszQgi (ចូលមើលថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១)

## ២.៦. ផលិតផលរបស់ក្រុមហ៊ុន BMW AG

BMW (**Bayerische Motoren Werke**) គឺជាក្រុមហ៊ុនផលិតរថយន្ត និងម៉ូតូឈានមុខគេមួយនៅលើពិភពលោកព្រមទាំងផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុ និងសេវាកម្មល្អបំផុត។ ក្រុមហ៊ុន BMW Group ជាក្រុមហ៊ុនមេរបស់យីហោរថយន្ត BMW MINI និង Rolls Royce ។ ក្រុមហ៊ុននេះមានម៉ាកផលិតផលដូចជា ៖ BMW, BMW I, BMW M, MINI, MINI Jonh Cooper Work, Rolls-Royce Motor Cars, Motorcycles, BMW Motorrad។ និងការផ្តល់សេវាកម្មរបស់ក្រុមហ៊ុន BMW Group មានដូចជា Alphabet, BMW Group Financial Services, Designworks។[31]

## ២.៧.ទីស្នាក់ការរបស់ BMW AG

ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន BMW AG មានទីតាំងនៅទីក្រុង Munich ប្រទេសអាល្លឺម៉ង់ ដែលមានរចនាបថយ៉ាងពិសេសបំផុត និងបានបើកដំណើរការជាង ៤0 ឆ្នាំមកហើយ។




*រូបភាពទី ៧ ៖ ទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុន **BMW AG** មានទីតាំងនៅទីក្រុង **Munich** ប្រទេសអាល្លឺម៉ង់*

[31] https://www.bmw.com/en-au/models/i-series.html (ចូលមើលថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០២១)

- អគារកម្ពស់ ១០១ ម៉ែត្រនេះត្រូវបានសាងសង់ឡើងនៅចន្លោះឆ្នាំ ១៩៦៨ និង ១៩៧២ ហើយបានបើកសម្ពោធនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ១៩៧៣។[32]
- រូបរាងខាងក្រៅរបស់អគារនេះ ត្រូវបានគេឌីហ្សាញដោយយកគំរូតាមទ្រង់ទ្រាយនៃស៊ីឡាំងបួនក្នុងម៉ាស៊ីនរថយន្តហើយមានអគារមួយទៀតតំណាងឲ្យក្បាលស៊ីឡាំង។ អំឡុងពេលសាងសង់នោះជាន់នីមួយៗត្រូវបានគេសាងសង់នៅជាន់ផ្ទាល់ដី បន្ទាប់មកទៀតទើបគេធ្វើការស្ទូចដាក់ជាជាន់ៗ។ អគារនេះមាន ២២ ជាន់ ដោយមានពីរជាន់ជាជាន់នៅក្រោមដី និង ១៨ ជាន់ជាការិយាល័យធ្វើការ។[33]
- អគាររាងស៊ីឡាំងទាំងបួនមិនបានស្ថិតនៅជាប់ដីនោះទេដោយពឹងផ្អែកលើអគារកណ្ដាលមួយ។
- ដោយសារមានរចនាបថពិសេស អគារទាំងពីរត្រូវបានគេចុះបញ្ជីជាអគារប្រវត្តិសាស្ត្រនៅឆ្នាំ ១៩៩៩ ដើម្បីធ្វើការអភិរក្ស។
- នៅឆ្នាំ ២០០៧ BMW Welt ដែលជាទីតាំងសម្រាប់តាំងបង្ហាញរថយន្ត BMW ត្រូវបានសាងសង់ឡើង នៅទល់មុខនឹង BMW Tower តែម្ដង៕

## ២.៨.រចនាសម្ព័ន្ធរបស់ BMW

រចនាសម្ព័នដឹកនាំ BMW និងរចនាសម្ព័ន្ធអង្គភាព BMW មានភាពស្មុគស្មាញច្រើនដែលឆ្លុះបញ្ចាំងពីទំហំអាជីវកម្ម និងទំហំប្រតិបត្តិការទូទាំងពិភពលោក។ ក្រុមប្រឹក្សាត្រួតពិនិត្យរថយន្ត BMW AG ស្ថិតនៅលើកំពូលនៃរចនាសម្ព័ន្ធអង្គភាពហើយមានសមាជិកចំនួន ២០ នាក់ ដែលត្រូវបានរៀបចំជាគណៈកម្មការចំនួនបួនផ្សេងគ្នាផងដែរ។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យ BMW AG មានការប្រជុំចំនួន ៥ នៅឆ្នាំ ២០១៥ ហើយការប្រជុំនីមួយៗតែងតែដោះស្រាយនូវបញ្ហាមួយចំនួនដែលជាលក្ខណៈយុទ្ធសាស្ត្រ។

[32] https://www.bmwgroup.com/en/general/approach-headquarters.html (ចូលមើលថ្ងៃទី ២៦ ឧសភា ២០២១)

[33] https://tech.sabay.com.kh/article/1207203 (ចូលមើលថ្ងៃទី ២៦ ឧសភា ២០២១)




***រូបភាពទី ៨៖ រចនាសម្ព័ន្ធដឹកនាំ BMW***

នៅពីក្រោមគណៈគ្រប់គ្រង គឺជាក្រុមប្រឹក្សាភិបាលរបស់ BMW AG ដែលក្នុងនោះមានសមាជិកទាំងអស់ចំនួន ៨ នាក់។ ក្រុមប្រឹក្សាភិបាលដឹកនាំដោយ Harald Krüger បានក្លាយជាប្រធានថ្មីនៃក្រុមប្រឹក្សាភិបាលនៅថ្ងៃទី ១៣ ខែឧសភាឆ្នាំ ២០១៥ ។ ក្រុមប្រឹក្សាភិបាលគ្រប់គ្រងដោយផ្ទាល់នូវគណៈកម្មាធិការអនុវត្តតាម BMW Group ហើយគណៈកម្មាធិការនេះរួមមានប្រធាននាយកដ្ឋានទាំង ៦ ដូចខាងក្រោមៈ

១. កិច្ចការច្បាប់, ប៉ាតង់
២. កិច្ចការសាជីវកម្មនិងរដ្ឋាភិបាល
៣. សវនកម្មសាជីវកម្ម
៤. ការអភិវឌ្ឍអង្គការ
៥. របាយការណ៍ក្រុម
៦. ធនធានមនុស្សសាជីវកម្មយុទ្ធសាស្ត្រនិងគោលដៅ

គណៈកម្មាធិការអនុវត្តតាមបណ្ដាញរថយន្ត BMW ប្រតិបត្តិការតាមរយៈការិយាល័យគណៈកម្មាធិការអនុវត្តច្បាប់របស់ក្រុមហ៊ុន BMW ដែលមានបុគ្គលិកចំនួន ១០ នាក់ដែលមានមូលដ្ឋាននៅទីស្នាក់ការកណ្ដាលក្នុងទីក្រុង Munich ។[34] ភារកិច្ចរបស់គេត្រូវបានបែងចែកជាពីរផ្នែក គឺ" ការអភិវឌ្ឍ និងសេវាកម្មអនុលោមភាព" និង " ប្រតិបត្តិការអនុលោមតាមក្រុម" ។ ការិយាល័យគណៈកម្មាធិការអនុវត្តច្បាប់នៃក្រុម BMW ត្រូវបានចាត់តាំងជាប្រធានក្រុមប្រឹក្សាភិបាលសម្រាប់គោលបំណងរៀបចំ។ រូបភាពក្រោមនេះបង្ហាញពីគំរូនៃប្រព័ន្ធអនុលោមភាពក្រុមហ៊ុន BMW

[34] https://research-methodology.net/bmw-leadership-and-bmw-organizational-structure (ចូលមើលថ្ងៃ ២៦ ឧសភា ២០២១)




*រូបភាពទី ៩ ៖ គំរូនៃប្រព័ន្ធអនុលោមភាពក្រុមហ៊ុន* ***BMW Group***

Group។ រចនាសម្ព័ន្ធរបស់ក្រុមហ៊ុន BMW ក៏បានរួមបញ្ចូលទាំងសមាសភាពនៃរចនាសម្ព័ន្ធដែលផ្អែកលើគម្រោងផងដែរ។ នេះជាការពិសេសណាស់សម្រាប់គម្រោងដែលទាក់ទងទៅនឹងការស្រាវជ្រាវ ការអភិវឌ្ឍ និងការដាក់ឲ្យដំណើរការរថយន្តស៊េរីថ្មី។

## ២.៩.សកម្មភាពអាជីវកម្ម

ក្រុមហ៊ុនផលិតរថយន្ត BMW មានទីស្នាក់ការធំនៅទីក្រុង Munich និងមានសាខាផលិតរថយន្តនៅប្រទេសមួយចំនួនដូចជាអាល្លឺម៉ង់ ប្រទេសប្រេស៊ីល ចិន ឥណ្ឌា មិកស៊ិកូ ហូឡង់ ប្រទេសអាហ្វ្រិកខាងត្បូង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក។

BMW Group (រួមទាំង Mini និង Rolls-Royce) បានផលិតរថយន្តចំនួន ១,៣៦៦,៨៣៨ គ្រឿងក្នុងឆ្នាំ ២០០៦ ហើយបន្ទាប់មកមានរថយន្តចំនួន ១,៤៨១,២៥៣ គ្រឿងក្នុងឆ្នាំ ២០១០ ។ ម៉ូតូរបស់ BMW កំពុងត្រូវបានផលិតនៅរោងចក្រ Berlin របស់ក្រុមហ៊ុនដែលមុននេះបានផលិតម៉ាស៊ីនយន្តហោះសម្រាប់ក្រុមហ៊ុន Siemens ។ ចំណែកឯសេវាកម្មហិរញ្ញវត្ថុ BMW Group គឺជាអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខគេក្នុងវិស័យរថយន្ត។ ដៃគូនិយោជិកប្រហែល ៨,០០០ នាក់ គឺជាដៃគូសហការជាមួយក្រុមហ៊ុនសម្រាប់ការលក់រាយរបស់យើងដើម្បីបម្រើជូនអតិថិជនទូទាំងពិភពលោក។ សកម្មភាពអាជីវកម្មសំខាន់ៗ គឺការផ្តល់ហិរញ្ញប្បទាន និងការជួលរថយន្ត និងម៉ូតូ

ម៉ាក BMW Group សម្រាប់អតិថិជនលក់រាយ និងពាណិជ្ជកម្ម។ សេវាកម្មហិរញ្ញវត្ថុរបស់ BMW Group ក៏ផ្តល់ជូនអតិថិជនឱ្យបានជ្រើសរើសនូវសេវាកម្មធានារ៉ាប់រង និងផលិតផលធនាគារផងដែរ។[35]

តាមវិធីនេះសេវាកម្មហិរញ្ញវត្ថុរបស់ BMW Group ដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងការយកចិត្តទុកដាក់របស់ BMW Group លើអតិថិជននិងដំណោះស្រាយ។ នៅឆ្នាំ ២០១១ រថយន្តម៉ាក BMW ប្រហែល ៥៦% ផលិតដោយម៉ាស៊ីនសាំងហើយ ៤៤% ទៀតដំណើរការដោយម៉ាស៊ីនម៉ាស៊ូត។ ក្នុងចំណោមរថយន្តប្រើសាំងទាំងនោះមានប្រហែល ២៧% ជាម៉ូដែលស៊ីឡាំង ៤ និងប្រហែល ៩% ជាម៉ូដែលស៊ីឡាំង ៨ ។ ជាមធ្យមរថយន្តចំនួន ៩,000 គ្រឿងក្នុងមួយថ្ងៃចេញពីរោងចក្រ BMW ហើយ ៦៣% ត្រូវបានដឹកដោយផ្លូវដែក។ រថយន្តត្រូវបានដាក់លក់នៅក្រោមស្លាកយីហោ BMW Mini និង Rolls-Royce ហើយម៉ូតូត្រូវបានដាក់លក់នៅក្រោមយីហោ BMW Motorrad ។ ក្នុងឆ្នាំ ២០១៧ BMW គឺជាអ្នកផលិតយានយន្តធំជាងគេទី ១៤ លើពិភពលោកដោយមានផលិតយានយន្តចំនួន ២.២៧៩.៥០៣ គ្រឿង។ ក្រុមហ៊ុនមានប្រវត្តិម៉ូតូសំខាន់ៗជាពិសេសក្នុង touring cars, Formula 1, sports cars និងកោះMan TT ។ សម្រាប់ចក្រភពអង់គ្លេស BMW មានរោងចក្រ Mini នៅជិត Oxford រោងចក្រនៅ Swindon និង Hams Hall និងមានកន្លែងដំឡើងរថយន្ត Rolls Royce នៅ Goodwood ។ នៅឆ្នាំ ២០២០ គ្រឿងបរិក្ខារទាំងនេះត្រូវបានបិទសម្រាប់រយៈពេលខ្លីចាប់ពីថ្ងៃទី ២៣ ខែមីនាដល់ថ្ងៃទី ១៧ ខែមេសាដោយសារការផ្ទុះឡើងនូវវីរុសកូរ៉ូណា។

យុទ្ធសាស្ត្រអាជីវកម្មរបស់ក្រុមហ៊ុន BMW គ្រុបគឺផ្អែកលើការមានរូបភាពយីហោដ៏មានឥទ្ធិពល។ យុទ្ធសាស្ត្រនេះបង្កើតបានជាមូលដ្ឋានគ្រឹះនៃភាពជោគជ័យរបស់ក្រុមហ៊ុន BMW Group ។ BMW Group ជឿជាក់លើការរក្សាតម្លៃស្នូលដូចជាបច្ចេកវិទ្យា ការច្នៃប្រឌិត ការសម្តែងចេញនូវគុណភាព ភាពជឿជាក់ ភាពផ្តាច់មុខ ព្រមទាំងការពេញចិត្តរបស់អតិថិជនផងដែរ។ ពាក្យស្លោករបស់ក្រុមហ៊ុន BMW Group ដែលភាសាអង់គ្លេសថា " បច្ចេកវិទ្យាបើកបរចុងក្រោយបំផុត" និង "ការបើកបររថយន្តប្រកបដោយភាពរីករាយ " វាបានធ្វើឲ្យយើងឃើញអំពីទិដ្ឋភាពទូទៅនៃយុទ្ធសាស្ត្រទីផ្សាររបស់ខ្លួនដែលប្រកាន់ខ្ជាប់។ យុទ្ធសាស្ត្ររបស់ក្រុមហ៊ុន BMW Group ត្រូវបានកំណត់យ៉ាងច្បាស់នៅលើគេហទំព័ររបស់ក្រុមហ៊ុន។ បេសកកម្មរបស់ BMW Group គឺជា " ក្រុមហ៊ុនផលិតរថយន្តដែលទទួលបានជោគជ័យបំផុតក្នុងឧស្សាហកម្មរថយន្ត" ដែលនេះជាយុទ្ធសាស្ត្រទីផ្សាររបស់ក្រុមហ៊ុន BMW Group។

[35] https://www.ukessays.com/essays/marketing/marketing-strategy (ចូលមើលថ្ងៃទី ២៦ ឧសភា ២០២១)

ភាពជោគជ័យរបស់ក្រុមហ៊ុនគឺផ្អែកលើវិធីសាស្ត្រ និងយុទ្ធសាស្ត្រផ្សព្វផ្សាយដែលមានប្រសិទ្ធភាព។ ក្រុមហ៊ុន BMW Group បានអនុវត្តយុទ្ធនាការទីផ្សារនៃគោលដៅអតិថិជនរបស់ខ្លួន។ នៅក្នុងពាក្យស្លោកពេលគឺ" បច្ចេកវិទ្យាចុងក្រោយបំផុត" និង " ភាពរីករាយក្នុងការបើកបរ" ។ ក្រុមហ៊ុន BMW បានប្រាប់អតិថិជនរបស់ខ្លួន ព្រមទាំងប្រជាជនដទៃទៀតថារថយន្ត BMW ផ្តល់នូវភាពរីករាយក្នុងការបើកបរដែលមិនមានរថយន្តផ្សេងទៀតអាចផ្តល់ឱ្យបាន។ យុទ្ធសាស្ត្រទីផ្សាររបស់ក្រុមហ៊ុន BMW ក៏មានយុទ្ធសាស្ត្រផ្សព្វផ្សាយដ៏រឹងមាំផងដែរ។ WCRS បានក្លាយជាភ្នាក់ងារផ្សាយពាណិជ្ជកម្មរបស់ BMW តាំងពីឆ្នាំ ១៩៧៩ និងបានបង្កើតរូបភាពយីហោមួយដ៏អស្ចារ្យសម្រាប់ BMW តាមរយៈយុទ្ធនាការផ្សាយពាណិជ្ជកម្មរួមមានតារាសម្តែងល្បី ៗ ដូចជា James Bond និង Tom Cruise ជាដើម។

យីហោរបស់ក្រុមហ៊ុន BMW Group រួមមាន BMW, MINI Cooper និង Rolls Royce ។ យីហោទាំងបីនិយាយដោយខ្លួនឯងថា និងមានភាពឆ្នើម។ ពួកគេទាំងអស់សុទ្ធតែមានសមត្ថភាពច្នៃប្រឌិតខ្ពស់ហើយអតិថិជនពិតជាមានអារម្មណ៍រីករាយក្នុងការបើកបរ។ នេះក៏ជាយុទ្ធសាស្ត្រអាជីវកម្មរបស់ BMW ផងដែរពោលគឺដើម្បីរក្សាកេរ្តិ៍ឈ្មោះម៉ាកល្បី។ យុទ្ធសាស្ត្រផ្សាយពាណិជ្ជកម្មដ៏អស្ចារ្យរបស់ក្រុមហ៊ុន BMW Group ក៏ជាហេតុផលសម្រាប់រូបភាពយីហោដ៏អស្ចារ្យរបស់ BMW ផងដែរ។ រូបភាពម៉ាកយីហោ BMW នេះត្រូវបានបង្កើតឡើងដោយប្រើការផ្សាយពាណិជ្ជកម្មចម្រុះពណ៌ជាង ៣០០ ។ ម៉ាកយីហោទាំង ៣ របស់ BMW គ្រុបគឺយីហោ BMW ផ្តោតលើរឿងមួយគឺ " អារម្មណ៍រីករាយក្នុងការបើកបរ "MINI មានភាពខុសប្លែកពីគេបន្តិច ចំណែកក្នុងឆ្នាំ ២០០៣ ក្រុមហ៊ុន Rolls Royce បានក្លាយជាផ្នែកមួយនៃក្រុមហ៊ុន BMW គ្រុបនិងជាម៉ាកដែលគួរឱ្យចាប់អារម្មណ៍ និងពេញនិយមបំផុតក្នុងចំណោមអតិថិជនគឺ" ឧត្តមភាពរថយន្តប្រណីត" ។[36]

## ២.១០.ដៃគូប្រកួតប្រជែងរបស់ក្រុមហ៊ុន BMW

BMW Group ជាក្រុមហ៊ុនផលិតរថយន្តឈានមុខគេលំដាប់ពិភពលោក។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយថ្មីៗនេះក្រុមហ៊ុន BMW Group ត្រូវបានកត់សម្គាល់យ៉ាងខ្លាំងក្លាបំផុតពីសំណាក់ដៃគូប្រកួតប្រជែងរបស់ខ្លួន។ ដៃគូប្រកួតប្រជែងធំ ៗ របស់ក្រុមហ៊ុន BMW Group រួមមាន Mercedes, Audi, Lexus, Ford, Porsche, Jaguar, Honda, Alfa Romeo ជាដើម។ ប៉ុន្តែដៃគូប្រកួតប្រជែងធំទាំងពីររបស់ BMW Group គឺ Mercedes-Benz និង

[36] https://www.bmwgroup.com/en/brands-and-services.html (ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១)

Audi ។ ក្នុងស្ថានភាពនេះក្រុមហ៊ុន BMW Group ត្រូវតែរក្សាយុទ្ធសាស្ត្រមួយដែល BMW Group មានប្រៀបលើដៃគូប្រកួតប្រជែងរបស់ខ្លួនក្នុងរយៈពេលវែង។[37]

**ការលក់ជាអន្តរជាតិ BMW និងការប្រៀបធៀប BMW, Audi និង Mercedes-Benz៖**

ការលក់រថយន្ត BMW Group បានថយចុះក្នុងឆ្នាំ ២០០៩ ដោយសារវិបត្តិសេដ្ឋកិច្ចប៉ុន្តែការលក់ថយចុះតិចជាងការរំពឹងទុក។ ការលក់រថយន្ត BMW Group ក្នុងឆ្នាំ ២០០៩ មានចំនួន ១,២៨៦,៣១០ គ្រឿង បើប្រៀបធៀបនឹងឆ្នាំ ២០០៨ ការលក់រថយន្ត BMW Group មានចំនួន ១,៤៣៥,៨៧៦ គ្រឿងនៅទូទាំងពិភពលោក។ ក្រុមហ៊ុន BMW Group ផ្តោតលើទីផ្សារអឺរ៉ុប និងអាមេរិកខាងជើង ពីព្រោះបណ្តាប្រទេសមានឧស្សាហកម្មច្រើនជាងគេនៅទ្វីបទាំងនេះ។ រហូតមកដល់ពេលនេះប្រទេសចិនកំពុងក្លាយជាទីផ្សារធំបំផុតសម្រាប់រថយន្ត BMW Group ហើយក៏កំពុងពង្រីកខ្លួននៅអាហ្វ្រិកខាងត្បូងក្នុងទ្វីបអាហ្វ្រិក និងប្រេស៊ីលផងដែរ។ ក្រុមហ៊ុន BMW Group ក៏កំពុងពង្រីកក្រុមហ៊ុនរបស់ខ្លួននៅក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួនដូចជាប៉ាគីស្ថាន ឥណ្ឌា និងបង់ក្លាដែស នៅក្នុងទីផ្សារអាស៊ីខាងត្បូង។ ក្រុមហ៊ុន Audi និង Mercedes-Benz បានលក់ដាច់សឹងតែប្រហាក់ប្រហែលជាមួយនឹងក្រុមហ៊ុន BMW។ ហើយក្រុមហ៊ុនទាំងពីរនេះមានការគំរាមកំហែងដ៏ធំបំផុតដល់ក្រុមហ៊ុន BMW នៅពេលខាងមុខដោយសារតែកំណើននៃការលក់របស់វាឡើងមកជិតស្មើ BMW។ យោងតាមតួលេខក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះក្រុមហ៊ុន BMW Group បានឈានមុខគេក្នុងការលក់រថយន្ត បន្ទាប់មកគឺរថយន្តម៉ាក Audi និង Mercedes-Benz ។ នៅឆ្នាំ ២០០៨ ការលក់រថយន្ត BMW Group មានចំនួន ១,៤៣៥,៨៧៦ គ្រឿងខណៈដែលក្រុមហ៊ុន Audi និង Mercedes-Benz លក់បាន ១.២២៣.៥០៦ និង ១.២៧៣.០១៣ រៀងៗខ្លួន។ នេះបង្ហាញថាបន្ទាប់ពីក្រុមហ៊ុន BMW Group រថយន្តម៉ាក Mercedes-Benz មានការលក់ដាច់បំផុត។ ក្នុងឆ្នាំ ២០០៩ ការលក់រថយន្ត BMW Group រថយន្តម៉ាក Audi និង Mercedes-Benz មានចំនួន ១.២៨៦.៣១០, ១.១៤៥.៣៦០ និង ១.០៩៣.៩០៥ រៀងៗខ្លួន។ តួលេខទាំងនេះបានបង្ហាញថាក្រុមហ៊ុន Mercedes-Benz មានការថយចុះនៃការលក់ហើយត្រូវបានទុករថយន្តចោលទៅវិញ។ ឥឡូវនេះគោលដៅរបស់រថយន្ត Audi នេះគឺដើម្បីចាប់រថយន្ត BMW Group ។[38]

---

[37] https://notesmatic.com/a-complete-list-of-bmw-competitors/ (ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១)

[38] https://www.ukessays.com/essays/marketing/marketing-strategy-and-pricing-strategy-of-bmw-marketing-essay.php (ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១)

ដើម្បីប្រឆាំងនឹងរថយន្ត Audi និង Mercedes-Benz ក្រុមហ៊ុន BMW Group ត្រូវតែបង្កើតយុទ្ធសាស្ត្រមួយដែលល្អជាងរថយន្ត Audi និង Mercedes-Benz ។ ក្រុមហ៊ុន BMW Group បាននូវអនុវត្តយុទ្ធសាស្ត្រថ្មីមួយគឺដើម្បីផ្តល់នូវផលិតផល និងសេវាកម្មដែលមានគុណភាពខ្ពស់ជាងមុនដល់អតិថិជន។ ក្រុមហ៊ុន BMW Group គួរតែស្វែងរកមធ្យោបាយកែលម្អការគ្រប់គ្រងចង្វាក់ផ្គត់ផ្គង់របស់ពួកគេ។ តាមរយៈការធ្វើបែបនេះពួកគេអាចកាត់បន្ថយថ្លៃដើមរថយន្តហើយអាចទទួលបានអត្ថប្រយោជន៍ច្រើនជាងគូប្រជែងរបស់ពួកគេ។[39]

[39] https://www.marketing91.com/top-12-bmw-competitors/ (ចូលមើលថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២១)

# ជំពូកទី ៣

# ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន

# BMW AG

# ជំពូកទី៣

# ការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG

នៅក្នុងជំពូកទី៣ នេះយើងធ្វើការសិក្សាអំពីការវិភាគរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG ដោយឧបករណ៍វិភាគនោះរួមមាន ការវិភាគតាមជួរដេក ការវិភាគតាមជួរឈរ និងការវិភាគតាមអនុបាត ហើយជាចុងក្រោយឈានទៅសន្និដ្ឋានពីស្ថានភាពទូទៅរបស់ក្រុមហ៊ុន។

## ៣.១. ការវិភាគតាមជួរដេក

### ៣.១.១. ការវិភាគតាមជួរដេកលើរបាយការណ៍លទ្ធផល

តារាងទី៥៖ ការវិភាគតាមជួរដេកលើរបាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន BMW AG

| BMW AG<br>INCOME STATEMENT FOR GROUP AND SEGMENTS | | | | |
|---|---|---|---|---|
| | | | **Increase or (Decrease) during 2020** | |
| In € million | **2020** | **2019** | **Amount** | **Percent** |
| Revenue | 98,990 | 104,210 | -5,220 | -5.0% |
| Cost of sales | -85,408 | -86,147 | -739 | -0.9% |
| **Gross profit** | **13,582** | **18,063** | **-4,481** | **-24.8%** |
| Selling and administrative expense | -8,795 | -9,367 | -572 | -6.1% |
| Operating income | 916 | 1,031 | -115 | -11.2% |
| Operating expense | -873 | -2,316 | -1,443 | -62.3% |
| **Profit before financial result** | **4,830** | **7,411** | **-2,581** | **-34.8%** |
| Result from equity accumulated investments | 920 | 136 | 784 | 576.5% |
| Interest income | 116 | 179 | -63 | -35.2% |
| Interest expenses | -458 | -499 | -41 | -8.2% |
| Other financial result | -186 | -109 | 77 | 70.6% |
| **Profit before tax** | **5,222** | **7,118** | **-1,896** | **-26.6%** |
| Income tax | -1,365 | -2,140 | -775 | -36.2% |
| **Profit from discontinuing operations** | **3,857** | **4,978** | **-1,121** | **-22.5%** |
| Profit from discontinued operations | – | 44 | – | – |
| **Net profit** | **3,857** | **5,022** | **-1,165** | **-23.2%** |

បំណកស្រាយ៖

យោងតាមការវិភាគរបាយការណ៍ហិរញ្ញវត្ថុតាមជួរដេក (Horizontal Analysis) លើរបាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន BMW AG បង្ហាញឲ្យឃើញថាគឺមានការប្រែប្រួលជាច្រើនទៅលើប្រតិបត្តិការគណនីនិមួយៗ៖

- ចំពោះការលក់ Revenue ក្នុងឆ្នាំ 2019 លក់បាន 104,210 លានអឺរ៉ូ។ រីឯឆ្នាំ ២០២០ ការលក់មានការថយចុះមកត្រឹម 98,990 លានអឺរ៉ូ ដែលមានការថយចុះ 5,220លានអឺរ៉ូ ត្រូវនឹង 5.0%។
- ចំពោះថ្លៃដើមវិញ Cost of sales ក្នុងឆ្នាំ 2020 គឺមានការថយចុះបើប្រៀបធៀបនឹងឆ្នាំ 2019 ដែលបានថយចុះចំនួន 739 លានអឺរ៉ូ ត្រូវនឹង 0.9%។
- ចំពោះចំណាយប្រតិបត្តិការវិញ Operating expense ក្នុងឆ្នាំ 2020 គឺមានការថយចុះបើប្រៀបធៀបនឹងឆ្នាំ 2019 ដែលបានថយចុះចំនួន 1,443 ត្រូវនឹង 62.3%
- ចំពោះប្រាក់ចំណេញ Net Profit ក្នុងឆ្នាំ ២០១៩ ចំណេញបាន 5,022 លានអឺរ៉ូ ហើយប្រាក់ចំណេញបានថយចុះមកត្រឹម 3,857 ក្នុងឆ្នាំ ២០២០ ដែលមានការថយចុះ 1,165 លានអឺរ៉ូ ត្រូវនឹង 23.2%។

ការថយចុះនៃប្រាក់ចំណេញអាចបណ្ដាលមកពីការថយចុះខ្លាំងនៃចំណូល ទោះបីជាថ្លៃដើម និងចំណាយប្រតិបត្តិការថយចុះក៏ដោយក៏មិនអាចទប់ទល់នឹងការធ្លាក់ចុះនៃចំណូលបានដែរ។

### ៣.១.២. ការវិភាគតាមជួរដេកលើតារាងតុល្យការ

តារាងទី៦៖ ការវិភាគតាមជួរដេកលើតារាងតុល្យការរបស់ក្រុមហ៊ុន BMW AG

| BMW AG<br>BALANCE SHEET FOR GROUP AND SEGMENTS | | | | |
|---|---|---|---|---|
| | | | **Increase or (Decrease) during 2020** | |
| In € million | **2020** | **2019** | **Amount** | **Percent** |
| **ASSETS** | | | | |
| Intangible assets | 12,342 | 11,729 | 613 | 5.2% |
| Property, plant and equipment | 21,850 | 23,245 | -1,395 | -6.0% |
| Leased products | 41,995 | 42,609 | -614 | -1.4% |
| Investments accounted for using equity method | 3,585 | 3,199 | 386 | 12.1% |
| Other investments | 735 | 703 | 32 | 4.6% |

| | | | | |
|---|---|---|---|---|
| Receivable from sales financing | 48,025 | 51,030 | -3,005 | -5.9% |
| Financial assets | 2,644 | 1,370 | 1,274 | 93.0% |
| Deferred tax | 2,459 | 2,194 | 265 | 12.1% |
| Other assets | 1,216 | 1,325 | -109 | -8.2% |
| **Non-current assets** | **134,851** | **137,404** | **-2,553** | **-1.9%** |
| Inventories | 14,896 | 15,891 | -995 | -6.3% |
| Trade receivables | 2,298 | 2,518 | -220 | -8.7% |
| Receivable from sales financing | 36,252 | 41,407 | -5,155 | -12.4% |
| Financial assets | 5,108 | 5,955 | -847 | -14.2% |
| Current tax | 606 | 1,209 | -603 | -49.9% |
| Other assets | 9,110 | 11,614 | -2,504 | -21.6% |
| Cash and cash equivalents | 13,537 | 12,036 | 1,501 | 12.5% |
| **Current assets** | **81,807** | **90,630** | **-8,823** | **-9.7%** |
| **Total assets** | **216,658** | **228,034** | **-11,376** | **-5.0%** |
| **EQUITY AND LIABILITIES** | | | | |
| Subscribed capital | 660 | 659 | 1 | 0.2% |
| Capital reserves | 2,199 | 2,161 | 38 | 1.8% |
| Revenue reserves | 59,550 | 57,667 | 1,883 | 3.3% |
| Accumulated other equity | -1,518 | -1,163 | 355 | 30.5% |
| **Equity attributable to shareholders of BMW AG** | **60,891** | **59,324** | **1,567** | **2.6%** |
| Minority interest | 629 | 583 | 46 | 7.9% |
| **Equity** | **61,520** | **59,907** | **1,613** | **2.7%** |
| Pension provisions | 3,693 | 3,335 | 358 | 10.7% |
| Other provisions | 6,488 | 5,788 | 700 | 12.1% |
| Deferred tax | 509 | 632 | -123 | -19.5% |
| Financial liabilities | 67,390 | 70,647 | -3,257 | -4.6% |
| Other liabilities | 5,095 | 5,100 | -5 | -0.1% |
| **Non-current provisions and liabilities** | **83,175** | **85,502** | **-2,327** | **-2.7%** |
| Other provisions | 7,494 | 7,421 | 73 | 1.0% |
| Current tax | 747 | 963 | -216 | -22.4% |

| | | | | |
|---|---|---|---|---|
| Financial liabilities | 38,986 | 46,093 | -7,107 | -15.4% |
| Trade payables | 8,644 | 10,182 | -1,538 | -15.1% |
| Other liabilities | 16,092 | 17,966 | -1,874 | -10.4% |
| **Current provisions and liabilities** | **71,963** | **82,625** | **-10,662** | **-12.9%** |
| **Total equity and liabilities** | **216,658** | **228,034** | **-11,376** | **-5.0%** |

បំណកស្រាយ៖

យោងតាមការវិភាគរបាយការណ៍ហិរញ្ញវត្ថុតាមជួរដេក (Horizontal Analysis) លើតារាងតុល្យការរបស់ក្រុមហ៊ុន BMW AG បង្ហាញឲ្យឃើញថាគឺមានការប្រែប្រួលមួយចំនួនដូចជាការបង្ហាញនៅខាងក្រោមនេះ៖

- ទ្រព្យសកម្មរយៈពេលខ្លី (Current assets) ក្នុងឆ្នាំ 2019 មាន 90,630 រីឯឆ្នាំ 2020 វិញ ទ្រព្យសកម្មរយៈពេលខ្លីថយចុះមកត្រឹម 81,807 ដែលមានការថយចុះ 8,823 លានអឺរ៉ូ ត្រូវនឹង 9.7%។
- ទ្រព្យសកម្មរយៈពេលវែង (Non-current assets) ក្នុងឆ្នាំ 2020 មានការថយចុះបើប្រៀបនឹងឆ្នាំ 2019 ដែលថយចុះចំនួន 2,553 លានអឺរ៉ូ ត្រូវនឹង1.9%។
- បំណុលរយៈពេលខ្លី (Current liabilities) ក្នុងឆ្នាំ 2019 មាន 82,625 លានអឺរ៉ូ ហើយបំណុលរយៈពេលខ្លីមានការថយចុះមកត្រឹម 71,963 លានអឺរ៉ូ ដែលថយចុះអស់ 10,662 ត្រូវនឹង 12.9%
- បំណុលរយៈពេលវែង (Non-current liabilities) ក្នុងឆ្នាំ 2020 មាន 83,175 លានអឺរ៉ូ បើប្រៀបធៀបនឹងឆ្នាំ 2019 ដែលថយចុះអស់ 2,327 លានអឺរ៉ូ ត្រូវនឹង 2.7%
- មូលធនម្ចាស់ភាគហ៊ុន (Equity) ក្នុងឆ្នាំ 2020 គឺមានការកើនឡើងបើប្រៀបធៀបនឹងឆ្នាំ 2019 ដែលកើនឡើង 1,613 លានអឺរ៉ូ ត្រូវនឹង2.7%។

## ៣.២. ការវិភាគតាមជួរឈរ

### ៣.២.១. ការវិភាគតាមជួរឈរលើរបាយការណ៍លទ្ធផល

តារាងទី៧៖ ការវិភាគតាមជួរឈរលើរបាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន BMW AG

| BMW AG<br>**INCOME STATEMENT FOR GROUP AND SEGMENTS** | | | | |
|---|---|---|---|---|
| | **2020** | | **2019** | |
| In € million | **Amount** | **Percent** | **Amount** | **Percent** |
| Revenue | 98,990 | 100.0% | 104,210 | 100.0% |
| Cost of sales | -85,408 | 86.3% | -86,147 | 82.7% |

| | | | | |
|---|---|---|---|---|
| **Gross profit** | **13,582** | 13.7% | **18,063** | 17.3% |
| Selling and administrative expense | -8,795 | 8.9% | -9,367 | 9.0% |
| Operating income | 916 | 0.9% | 1,031 | 1.0% |
| Operating expense | -873 | 0.9% | -2,316 | 2.2% |
| **Profit before financial result** | **4,830** | 4.9% | **7,411** | 7.1% |
| Result from equity accumulated investments | 920 | 0.9% | 136 | 0.1% |
| Interest income | 116 | 0.1% | 179 | 0.2% |
| Interest expenses | -458 | 0.5% | -499 | 0.5% |
| Other financial result | -186 | 0.2% | -109 | 0.1% |
| **Profit before tax** | **5,222** | 5.3% | **7,118** | 6.8% |
| Income tax | -1,365 | 1.4% | -2,140 | 2.1% |
| **Profit from discontinuing operations** | **3,857** | 3.9% | **4,978** | 4.8% |
| Profit from discontinued operations | – | – | 44 | 0.0% |
| **Net profit** | **3,857** | 3.9% | **5,022** | 4.8% |

បំណកស្រាយ៖

- បើធៀបនឹងចំណូលសរុប ថ្លៃដើម (Cost of sales) របស់ក្រុមហ៊ុននៅក្នុងឆ្នាំ ២០២០ មាន ៨៦,៣% ដែលមានការកើនឡើងបើធៀបនឹងឆ្នាំ 2019 ដែលមានត្រឹមតែ ៨២,៧% តែប៉ុណ្ណោះ។
- ប្រាក់ចំណេញដុល (Gross profit) របស់ក្រុមហ៊ុននៅក្នុងឆ្នាំ 2019 ស្មើនឹង 17.3% រីឯឆ្នាំ 2020 ស្មើនឹង 13.7%។ យើងសង្កេតឃើញថានៅឆ្នាំ ២០២០ ប្រាក់ចំណេញដុលមានការថយចុះ 3.6% បើធៀបនឹងឆ្នាំ 2019។
- ប្រាក់ចំណេញមុនពេលបង់ពន្ធ (Profit before tax) របស់ក្រុមហ៊ុននៅក្នុងឆ្នាំ 2019 ស្មើនឹង 6.8% នៃចំណូលសរុប ហើយនៅឆ្នាំ 2020 ស្មើនឹង 5.3% នៃចំណូលសរុប។ យើងសង្កេតឃើញថានៅឆ្នាំ ២០២០ ប្រាក់ចំណេញមុនពេលបង់ពន្ធមានការថយចុះ 1.5% បើធៀបនឹងឆ្នាំ 2019។
- ប្រាក់ចំណេញសុទ្ធ (Net profit) របស់ក្រុមហ៊ុនក្នុងឆ្នាំ 2019 មានចំនួន 5,022 លានអឺរ៉ូ ដែលស្មើនឹង 4.8% នៃចំណូលសរុបចំនួន 104,210 លានអឺរ៉ូ រីឯឆ្នាំ 2020 មានចំនួន 3,857 លានអឺរ៉ូ ដែលស្មើនឹង 3.9% នៃចំណូលសរុបចំនួន 98,990 លានអឺរ៉ូ។ យើងសង្កេតឃើញថាប្រាក់ចំណេញសុទ្ធមានការថយចុះ (0.9%) បើធៀបនឹងឆ្នាំ 2019។

## ៣.២.២. ការវិភាគតាមជួរឈរលើតារាងតុល្យការ

តារាងទី៨៖ ការវិភាគតាមជួរឈរលើតារាងតុល្យការរបស់ក្រុមហ៊ុន BMW AG

| BMW AG<br>**BALANCE SHEET FOR GROUP AND SEGMENTS** | | | | |
|---|---|---|---|---|
| | **2020** | | **2019** | |
| In € million | **Amount** | **Percent** | **Amount** | **Percent** |
| **ASSETS** | | | | |
| Intangible assets | 12,342 | 5.7% | 11,729 | 5.1% |
| Property, plant and equipment | 21,850 | 10.1% | 23,245 | 10.2% |
| Leased products | 41,995 | 19.4% | 42,609 | 18.7% |
| Investments accounted for using equity method | 3,585 | 1.7% | 3,199 | 1.4% |
| Other investments | 735 | 0.3% | 703 | 0.3% |
| Receivable from sales financing | 48,025 | 22.2% | 51,030 | 22.4% |
| Financial assets | 2,644 | 1.2% | 1,370 | 0.6% |
| Deferred tax | 2,459 | 1.1% | 2,194 | 1.0% |
| Other assets | 1,216 | 0.6% | 1,325 | 0.6% |
| **Non-current assets** | **134,851** | **62.2%** | **137,404** | **60.3%** |
| Inventories | 14,896 | 6.9% | 15,891 | 7.0% |
| Trade receivables | 2,298 | 1.1% | 2,518 | 1.1% |
| Receivable from sales financing | 36,252 | 16.7% | 41,407 | 18.2% |
| Financial assets | 5,108 | 2.4% | 5,955 | 2.6% |
| Current tax | 606 | 0.3% | 1,209 | 0.5% |
| Other assets | 9,110 | 4.2% | 11,614 | 5.1% |
| Cash and cash equivalents | 13,537 | 6.2% | 12,036 | 5.3% |
| **Current assets** | **81,807** | **37.8%** | **90,630** | **39.7%** |
| **Total assets** | **216,658** | **100.0%** | **228,034** | **100.0%** |
| **EQUITY AND LIABILITIES** | | | | |
| Subscribed capital | 660 | 0.3% | 659 | 0.3% |
| Capital reserves | 2,199 | 1.0% | 2,161 | 0.9% |

| | | | | |
|---|---|---|---|---|
| Revenue reserves | 59,550 | 27.5% | 57,667 | 25.3% |
| Accumulated other equity | -1,518 | 0.7% | -1,163 | 0.5% |
| **Equity attributable to shareholders of BMW AG** | **60,891** | **28.1%** | **59,324** | **26.0%** |
| Minority interest | 629 | 0.3% | 583 | 0.3% |
| **Equity** | **61,520** | **28.4%** | **59,907** | **26.3%** |
| Pension provisions | 3,693 | 1.7% | 3,335 | 1.5% |
| Other provisions | 6,488 | 3.0% | 5,788 | 2.5% |
| Deferred tax | 509 | 0.2% | 632 | 0.3% |
| Financial liabilities | 67,390 | 31.1% | 70,647 | 31.0% |
| Other liabilities | 5,095 | 2.4% | 5,100 | 2.2% |
| **Non-current provisions and liabilities** | **83,175** | **38.4%** | **85,502** | **37.5%** |
| Other provisions | 7,494 | 3.5% | 7,421 | 3.3% |
| Current tax | 747 | 0.3% | 963 | 0.4% |
| Financial liabilities | 38,986 | 18.0% | 46,093 | 20.2% |
| Trade payables | 8,644 | 4.0% | 10,182 | 4.5% |
| Other liabilities | 16,092 | 7.4% | 17,966 | 7.9% |
| **Current provisions and liabilities** | **71,963** | **33.2%** | **82,625** | **36.2%** |
| **Total equity and liabilities** | **216,658** | **100.0%** | **228,034** | **100.0%** |

បំណកស្រាយ៖

- បើធៀបនឹងទ្រព្យសកម្មសរុប ទ្រព្យសកម្មរយៈពេលខ្លី (Current assets) របស់ក្រុមហ៊ុននៅក្នុងឆ្នាំ 2019 ស្មើនឹង 39,7% រីឯឆ្នាំ 2020 ស្មើនឹង 37.8% ។ យើងសង្កេតឃើញថានៅឆ្នាំ ២០២០ ទ្រព្យសកម្មរយៈពេលខ្លីមានការថយចុះ 1.9% បើធៀបនឹងឆ្នាំ 2019។
- ទ្រព្យសកម្មរយៈពេលវែង (Non-current assets) របស់ក្រុមហ៊ុនក្នុងឆ្នាំ 2019 ស្មើនឹង 60.3% ហើយឆ្នាំ 2020 វិញ ស្មើនឹង 62,2% ។ យើងសង្កេតឃើញថានៅឆ្នាំ ២០២០ ទ្រព្យសកម្មរយៈពេលវែងមានការកើនឡើង 1.9% បើធៀបនឹងឆ្នាំ 2019។

- បើធៀបនឹងបំណុលសរុប បំណុលរយៈពេលខ្លី (Current liabilities) របស់ក្រុមហ៊ុនក្នុងឆ្នាំ 2019 ស្មើនឹង 36.2% រីឯឆ្នាំ2020 វិញស្មើនឹង 33.2%។ យើងសង្កេតឃើញថានៅឆ្នាំ ២០២០ បំណុលរយៈពេលខ្លីមានការថយចុះ 3% បើធៀបនឹងឆ្នាំ 2019
- បំណុលរយៈពេលវែង (Non-current liabilities) របស់ក្រុមហ៊ុនក្នុងឆ្នាំ 2019 ស្មើនឹង 37.5% ហើយនៅឆ្នាំ 2020 ស្មើនឹង 38,4%។ យើងសង្កេតឃើញថានៅឆ្នាំ ២០២០ បំណុលរយៈពេលវែងមានការកើនឡើង 0.9% បើធៀបនឹងឆ្នាំ 2019
- មូលធនម្ចាស់ភាគហ៊ុន (Equity) របស់ក្រុមហ៊ុនក្នុងឆ្នាំ 2019 មានចំនួន 59,907 ដែលស្មើនឹង 26,3% នៃបំណុល និងមូលធនម្ចាស់ភាគហ៊ុនសរុបចំនួន 228,034 លានអឺរ៉ូ រីឯឆ្នាំ 2020 មានចំនួន 61,520 ដែលស្មើនឹង 28,4% នៃបំណុល និងមូលធនម្ចាស់ភាគហ៊ុនសរុបចំនួន 216,658 លានអឺរ៉ូ។ យើងសង្កេតឃើញថាមូលធនម្ចាស់ភាគហ៊ុនមានការកើនឡើង 2.1% បើធៀបនឹងឆ្នាំ 2019។

## ៣.៣. ការវិភាគតាមអនុបាត

ក្នុងការវិភាគតាមអនុបាតនេះយើងបែងចែកអនុបាតជាបីផ្នែកមានដូចជាៈ អនុបាតសន្ទនីយភាព អនុបាតលទ្ធភាពទូទាត់បំណុល និងអនុបាតសមត្ថភាពស្វែងរកប្រាក់ចំណេញ។

### ៣.៣.១. អនុបាតសន្ទនីយភាព

#### ក. អនុបាតចរន្ត (Current Ratio)

$$\text{Current Ratio} = \frac{\text{Current Assets}}{\text{Current Liabilities}}$$

តារាងទី៩៖ អនុបាតចរន្តរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Current Asset | 90,630 | 81,807 |
| B. Current Liabilities | 82,625 | 71,963 |
| A/B. Current Ratio | 109.69% | 113.68% |
| Change | - | +3.99% |

ក្រាហ្វិចទី១៖ អនុបាតចរន្តរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




យោងតាមតារាងខាងលើបញ្ជាក់ថា ផលធៀបរវាងទ្រព្យសកម្មរយៈពេលខ្លី ជាមួយនឹងបំណុលរយៈពេលខ្លីក្នុងឆ្នាំ ២០១៩ ស្មើនឹង ១០៩,៦៩% មានន័យថាក្នុង ១០០ អឺរ៉ូនៃបំណុលរយៈពេលខ្លីក្រុមហ៊ុនមានទ្រព្យសកម្មរយៈពេលខ្លីចំនួន ១០៩,៦៩ អឺរ៉ូសម្រាប់ទូទាត់។ ចំណែកឯក្នុងឆ្នាំ ២០២០ វិញរាល់ ១០០ អឺរ៉ូនៃបំណុលរយៈពេលខ្លីក្រុមហ៊ុនមានទ្រព្យសកម្មរយៈពេលខ្លីចំនួន ១១៣,៦៨ អឺរ៉ូសម្រាប់ទូទាត់ ដែលយើងសង្កេតឃើញថានៅក្នុងឆ្នាំ ២០២០ មានអត្រាកើនឡើង ៣,៩៩%។

### ខ. អនុបាតរហ័ស (Quick Ratio)

$$\text{Quick Ratio} = \frac{\text{Current Assets} - \text{Inventory}}{\text{Current Liabilities}}$$

តារាងទី១០៖ អនុបាតរហ័សរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Current Assets | 90,630 | 81,807 |
| B. Inventory | 15,891 | 14,896 |
| C. Current Liabilities | 82,625 | 71,963 |
| A-B/C. Quick Ratio | 90.46% | 92.98% |
| Change | - | 2.52% |

ក្រាហ្វិចទី២៖ អនុបាតរហ័សរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




យោងតាមតារាងខាងលើបញ្ជាក់ថា ផលធៀបរវាងទ្រព្យសកម្មរហ័សនឹងបំណុលរយៈពេលខ្លីក្នុងឆ្នាំ ២០១៩ ស្មើនឹង ៩០,៤៦% មានន័យថាក្នុង ១០០ អឺរ៉ូនៃបំណុលរយៈពេលខ្លី នោះក្រុមហ៊ុនមានទ្រព្យសកម្មរហ័សចំនួន ៩០,៤៦ អឺរ៉ូសម្រាប់ទូទាត់ ហើយក្នុងឆ្នាំ ២០២០ វិញ គឺមានទ្រព្យសកម្មរហ័សចំនួន ៩២,៩៨ អឺរ៉ូសម្រាប់ទុកទូទាត់ ដែលឃើញថានៅក្នុងឆ្នាំ ២០២០ មានអត្រាកើនឡើង ២,៥២% បើធៀបនឹងឆ្នាំ ២០១៩។

### គ. អនុបាតបង្វិលជុំនៃឥណទេយ្យ ( Receivable Turnover)

$$\text{Receivable Turnover} = \frac{\text{Net Sales}}{\text{Net Account Receivable}}$$

តារាងទី១១៖ អនុបាតបង្វិលជុំនៃឥណទេយ្យរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 | 2020 |
|---|---|---|
| A. Net Sales | 104,210 | 98,990 |
| B. Net Account Receivable | 43,925 | 38,550 |
| A/B. Receivable Turnover | 2.37 | 2.57 |
| Change | - | +0.2 |

ក្រាហ្វិចទី៣៖ អនុបាតបង្វិលជុំនៃឥណទេយ្យរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




ក្នុងឆ្នាំ ២០១៩ ផលលក់សរុបធៀបជាមួយនឹងឥណទេយ្យ ស្មើនឹង ២,៣៧ មានន័យថានៅក្នុងឆ្នាំ ២០១៩ ក្រុមហ៊ុនអាចបង្វិលឥណទេយ្យបានចំនួន ២,៣៧ ដងនៅក្នុងមួយឆ្នាំ។ ឯឆ្នាំ ២០២០ វិញផលធៀប ស្មើនឹង ២,៥៧ មានន័យថាក្នុងឆ្នាំ ២០២០ ក្រុមហ៊ុនអាចបង្វិលឥណទេយ្យបានចំនួន ២,៥៧ ដងក្នុងមួយឆ្នាំ។ តាមរយៈអនុបាតនេះយើងសង្កេតឃើញថាការបង្វិលឥណទេយ្យរបស់ក្រុមហ៊ុនមានការកើនឡើង ០,២ ដង បើធៀបជាមួយនឹងឆ្នាំ ២០១៩។

- **ចំនួនថ្ងៃនៃការបង្វិលឥណទេយ្យ (Days′ Sales in Receivable)**

$$\text{Days' Sales in Receivable} = \frac{\text{365 days}}{\text{Receivable Turnover}}$$

តារាងទី១២៖ ចំនួនថ្ងៃនៃការប្រមូលឥណទេយ្យរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 | 2020 |
|---|---|---|
| A. 365 days | 365 | 365 |
| B. Receivable Turnover | 2.37 | 2.57 |
| A/B. Days′ Sales in Receivable | 154 | 142 |
| Change | - | -12 |

ក្រាហ្វិចទី៤៖ អនុបាតចំនួនថ្ងៃនៃការប្រមូលឥណទេយ្យរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




តាមរយៈអនុបាតខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០១៩ ស្មើនឹង ១៥៤ មានន័យថាក្រុមហ៊ុនចំណាយពេលវេលាជាមធ្យម ១៥៤ ថ្ងៃនៅក្នុងការប្រមូលឥណទេយ្យម្តងៗ ឯឆ្នាំ ២០២០ វិញចំនួនថ្ងៃនៃការបង្វិលឥណទេយ្យបានថយចុះមកត្រឹម ១៤២ថ្ងៃ មានន័យថាក្រុមហ៊ុនចំណាយពេលវេលាជាមធ្យម ១៤២ ថ្ងៃក្នុងការបង្វិលឥណទេយ្យម្តងៗ។ យើងសង្កេតឃើញថាចំនួនថ្ងៃនៃការប្រមូលឥណទេយ្យមានការថយចុះ ១២ ថ្ងៃបើធៀបនឹងឆ្នាំ ២០១៩។

**ឃ. អនុបាតបង្វិលជុំនៃសន្និធិ (Inventory Turnover)**

$$\text{Inventory Turnover} = \frac{\text{Cost of Goods Sold}}{\text{Inventory}}$$

តារាងទី១៣៖ អនុបាតបង្វិលជុំនៃសន្និធិរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 | 2020 |
|---|---|---|
| A. Cost of goods sold | 86,147 | 85,408 |
| B. Inventory | 15,891 | 14,896 |
| A/B. Inventory Turnover | 5.42 | 5.73 |
| Change | - | +0.31 |

ក្រាហ្វិចទី៥៖ អនុបាតបង្វិលជុំនៃសន្និធិរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




ចំណាយថ្លៃដើមធៀបជាមួយសន្និធិនៅក្នុងឆ្នាំ ២០១៩ ស្មើនឹង ៥,៤២ មានន័យថាក្នុងឆ្នាំ ២០១៩ ក្រុមហ៊ុនអាចបង្វិលសន្និធិបានចំនួន ៥,៤២ ដងក្នុងមួយឆ្នាំ ហើយនៅក្នុងឆ្នាំ ២០២០ ស្មើនឹង ៥,៧៣ មានន័យថាក្នុងឆ្នាំ ២០២០ ក្រុមហ៊ុនអាចបង្វិលសន្និធិបានចំនួន ៥,៧៣ ដងក្នុងមួយឆ្នាំ។ តាមរយៈអនុបាតនេះយើងសង្កេតឃើញថា ការលក់សន្និធិរបស់ក្រុមហ៊ុនមានការកើនឡើង ០,៣១ ដងបើធៀបជាមួយនឹងឆ្នាំ ២០១៩។

- **ចំនួនថ្ងៃនៃការលក់សន្និធិ (Days′ Sales in Inventory)**

$$\text{Days′ Sales in Inventory} = \frac{\text{365 days}}{\text{Inventory Turnover}}$$

តារាងទី១៤៖ ចំនួនថ្ងៃនៃការលក់សន្និធិរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 | 2020 |
|---|---|---|
| A. 365 days | 365 | 365 |
| B. Inventory Turnover | 5.42 | 5.73 |
| A/B. Days′ Sales in Inventory | 67 | 64 |
| Change | - | -3 |

ក្រាហ្វិចទី៦៖ អនុបាតចំនួនថ្ងៃនៃការលក់សន្និធិរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




តាមអនុបាតខាងលើ យើងសង្កេតឃើញថា នៅក្នុងឆ្នាំ ២០១៩ ស្មើនឹង ៦៧ មានន័យថាជាមធ្យមក្រុមហ៊ុន ប្រើប្រាស់រយៈពេល ៦៧ថ្ងៃក្នុងការលក់សន្និធិម្តងៗ រីឯនៅក្នុងឆ្នាំ ២០២០ វិញ ក្រុមហ៊ុនត្រូវការពេលវេលាជាមធ្យម ៦៤ ថ្ងៃក្នុងការលក់ចេញនូវសន្និធិម្តងៗ។

យោងតាមការវិភាគលើអនុបាតចរន្ត អនុបាតរហ័ស បង្វិលជុំនៃឥណទេយ្យ និងបង្វិលជុំនៃសន្និធិ យើងអាចសន្និដ្ឋានបានថានៅក្នុងឆ្នាំ ២០២០ ក្រុមហ៊ុនមានលទ្ធភាពទូទាត់បំណុលរយៈពេលខ្លីល្អប្រសើរជាងឆ្នាំ ២០១៩។

### ៣.៣.២. អនុបាតនៃលទ្ធភាពទូទាត់បំណុល

#### ក. អនុបាតបំណុលធៀបជាមួយទ្រព្យសកម្ម (Debt to Assets Ratio)

$$\text{Total Debt to Asset Ratio} = \frac{\text{Total Liabilities}}{\text{Total Assets}}$$

តារាងទី១៥៖ អនុបាតបំណុលធៀបជាមួយនឹងទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Total Liabilities | 168,127 | 155,138 |
| B. Total Assets | 228,034 | 216,658 |
| A/B. Total Debt Ratio | 73.73% | 71.61% |
| Change | - | -2.12% |

ក្រាហ្វិចទី៧៖ អនុបាតបំណុលធៀបជាមួយនឹងទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




នៅឆ្នាំ ២០១៩ផលធៀបរវាងបំណុលសរុបជាមួយនឹងទ្រព្យសកម្មសរុប ស្មើនឹង ៧៣,៧៣% មានន័យថា រាល់ ១០០ អឺរ៉ូនៃទ្រព្យសកម្មដែលក្រុមហ៊ុនមាន ក្រុមហ៊ុនបានប្រើប្រាស់បំណុលចំនួន ៧៣,៧៣ អឺរ៉ូ។ ចំណែកឯនៅក្នុងឆ្នាំ ២០២០ វិញផលធៀបនេះស្មើនឹង ៧១,៦១% មានន័យថារាល់ ១០០ អឺរ៉ូនៃទ្រព្យសកម្មក្រុមហ៊ុនបានប្រើប្រាស់បំណុលចំនួន ៧១,៦១ អឺរ៉ូ ដែលមានការថយចុះអស់ ២,១២% បើធៀបជាមួយនឹងឆ្នាំ ២០១៩។ ការថយចុះនៃអនុបាតនេះបង្ហាញឱ្យឃើញថាលទ្ធភាពទូទាត់បំណុលរបស់ក្រុមហ៊ុននៅឆ្នាំ ២០២០ ល្អប្រសើរជាងឆ្នាំ ២០១៩ ករណីក្រុមហ៊ុនមានបញ្ហា។

### ខ. អនុបាតបំណុលធៀបនឹងមូលធន (Debt to Equity Ratio)

$$\text{Debt to Equity Ratio} = \frac{\text{Total Liabilities}}{\text{Total Equity}}$$

តារាងទី១៦៖ បំណុលធៀបនឹងមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Total Liabilities | 168,127 | 155,138 |
| B. Total Equity | 59,907 | 61,520 |
| A/B. Debt to Equity Ratio | 2.81 | 2.52 |
| Change | - | -0.29 |

ក្រាហ្វិចទី៨៖ អនុបាតបំណុលធៀបនឹងមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




នៅក្នុងឆ្នាំ ២០១៩ បំណុលសរុបស្មើនឹង ២,៨១ដងនៃមូលធន ចំណែកឯឆ្នាំ ២០២០ ក្រុមហ៊ុនបានប្រើប្រាស់បំណុលអស់ ២,៥២ ដងនៃមូលធន។ យើងសង្កេតឃើញថាការប្រើប្រាស់បំណុលជាមួយនឹងមូលធនមានការថយចុះ ០,២៩ ដងបើធៀបនឹងឆ្នាំ ២០១៩។

### គ. មេគុណមូលធន (Equity Multiplier)

$$\text{Equity Multiplier} = \frac{\text{Total Assets}}{\text{Total Equity}}$$

តារាងទី១៧៖ មេគុណមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 | 2020 |
|---|---|---|
| A. Total Assets | 228,034 | 216,658 |
| B. Total Equity | 59,907 | 61,520 |
| A/B. Equity Multiplier | 3.81 | 3.52 |
| Change | - | -0.29 |

ក្រាហ្វិចទី៩៖ អនុបាតមេគុណមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




យោងតាមតារាងខាងលើបង្ហាញថា ផលធៀបរវាងទ្រព្យសកម្មសរុបជាមួយនឹងមូលធនម្ចាស់ទ្រព្យក្នុងឆ្នាំ ២០១៩ ស្មើនឹង ៣,៨១ មានន័យថាទ្រព្យសកម្មសរុបស្មើ ៣,៨១ ដងនៃមូលធន ហើយនៅឆ្នាំ ២០២០ វិញ ផលធៀបនេះមានការធ្លាក់ចុះវិញបន្តិចត្រឹមតែ ៣,៥២ មានន័យថាទ្រព្យសកម្មសរុបស្មើនឹង ៣,៥២ ដងនៃមូលធនសរុប គឺមានការថយចុះបន្តិចចំនួន ០,២៩ដង បើធៀបនឹងឆ្នាំ ២០១៩។

**ឃ.អនុបាតនៃលទ្ធភាពទូទាត់ការប្រាក់ (Times Interest Earned Ratio)**

$$\text{Times Interest Earned Ratio} = \frac{\text{Earning Before Interest and Tax(EBIT)}}{\text{Interest Expense}}$$

តារាងទី១៨៖ អនុបាតនៃលទ្ធភាពទូទាត់ការប្រាក់របស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 | 2020 |
|---|---|---|
| A. EBIT | 5,222 | 7,118 |
| B. Interest Expense | 499 | 458 |
| A/B. Time Interest Earned | 10.46 | 15.54 |
| Change | - | +5.08 |

ក្រាហ្វិចទី១០៖ អនុបាតលទ្ធភាពទូទាត់ការប្រាក់របស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




តាមតារាងខាងលើ យើងឃើញថានៅក្នុងឆ្នាំ ២០១៩ ប្រាក់ចំណេញមុនបង់ការប្រាក់ និងបង់ពន្ធ អាចទូទាត់ការប្រាក់បាន ១០,៤៦ ដង ហើយនៅក្នុងឆ្នាំ ២០២០ អាចទូទាត់ការប្រាក់បាន ១៥,៥៤ ដង ដែលមានការកើនឡើងចំនួន ៥,០៨ ដង បើធៀបនឹងឆ្នាំមុន។

ជាសរុបមក តាមរយៈការសិក្សាទៅលើអនុបាត Total Debt Ratio Debt to Equity Ratio និងEquity Multiplier នៅឆ្នាំ ២០២០ ក្រុមហ៊ុនប្រើប្រាស់បំណុលតិចជាងជាងឆ្នាំ ២០១៩ ដែលបញ្ជាក់ឃើញថាករណីក្រុមហ៊ុនមានបញ្ហានោះក្រុមហ៊ុនអាចមានលទ្ធភាពទូទាត់បំណុលបានល្អប្រសើរជាង តាមរយៈការលក់ទ្រព្យសកម្ម ឬប្រើប្រាស់មូលធនម្ចាស់ភាគហ៊ុនមកទូទាត់បំណុល។ មួយវិញទៀត បើពឹងផ្អែកទៅលើអនុបាតទូទាត់ការប្រាក់ នៅឆ្នាំ ២០២០ ក៏អាចទូទាត់ការប្រាក់បានច្រើនដងជាង។ យើងអាចសន្និដ្ឋានថា សមត្ថភាពទូទាត់បំណុលរបស់ក្រុមហ៊ុននៅឆ្នាំ ២០២០ គឺល្អប្រសើរជាងឆ្នាំ ២០១៩។

### ៣.៣.៣. អនុបាតសមត្ថភាពស្វែងរកប្រាក់ចំណេញ

#### ក. អនុបាតប្រាក់ចំណេញសុទ្ធ (Profit Margin Ratio)

$$\text{Profit Margin} = \frac{\text{Net Income}}{\text{Net Sales}}$$

តារាងទី១៩៖ អនុបាតប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Net Income | 5,022 | 3,857 |
| B. Net Sales | 104,210 | 98,990 |
| A/B. Profit Margin | 4.82% | 3.90% |
| Change | - | -0.92 |

ក្រាហ្វិចទី១១៖ អនុបាតប្រាក់ចំណេញសុទ្ធរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




ផលធៀបរវាងប្រាក់ចំណេញសុទ្ធ ជាមួយនឹងចំណូលនៃការលក់សុទ្ធក្នុងឆ្នាំ ២០១៩ ស្មើនឹង ៤,៨២% មានន័យថារាល់ ១០០ អឺរ៉ូនៃប្រាក់ចំណូលក្រុមហ៊ុនបង្កើតបានប្រាក់ចំណេញ ៤,៨២ អឺរ៉ូ (ចំណាយអស់ ៩៥,១៨ អឺរ៉ូ)។ ចំណែកនៅក្នុងឆ្នាំ ២០២០ វិញរាល់ ១០០ អឺរ៉ូនៃប្រាក់ចំណូលក្រុមហ៊ុនបង្កើតបានប្រាក់ចំណេញ ៣,៩០ អឺរ៉ូ (ចំណាយអស់ ៩៦,១០ អឺរ៉ូ)ដែលមានការធ្លាក់ចុះបើធៀបជាមួយនឹងឆ្នាំ ២០១៩ អស់ចំនួន ០,៩២% ការធ្លាក់ចុះនេះបង្ហាញថាសមត្ថភាពគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុននៅឆ្នាំ ២០២០ នេះមិនសូវបានល្អបើធៀបនឹងឆ្នាំ ២០១៩។

### ខ. អនុបាតបង្វិលទ្រព្យសកម្ម (Asset Turnover)

$$\text{Asset Turnover} = \frac{\text{Net Sales}}{\text{Total Assets}}$$

តារាងទី២០៖ អនុបាតបង្វិលទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Net Sales | 104,210 | 98,990 |
| B. Total Assets | 228,034 | 216,658 |
| A/B. Asset Turnover | 45.70% | 45.69% |
| Change | - | -0.01 |

ក្រាហ្វិចទី១២៖ អនុបាតបង្វិលទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




នៅក្នុងឆ្នាំ ២០១៩ ផលធៀបរវាងការលក់សរុប និងទ្រព្យសកម្មសរុប មាន ៤៥,៧០% មានន័យថារាល់ការវិនិយោគ ១០០ អឺរ៉ូទៅលើទ្រព្យសកម្មនោះក្រុមហ៊ុនអាចបង្កើតចំណូលបាន ៤៥,៧០ អឺរ៉ូ ហើយនៅក្នុងឆ្នាំ ២០២០ វិញ រាល់ការវិនិយោគ ១០០ អឺរ៉ូទៅលើទ្រព្យសកម្មនោះក្រុមហ៊ុនអាចបង្កើតចំណូលបាន ៤៥,៦៩ អឺរ៉ូ។

**គ. អនុបាតផលចំណេញពីទ្រព្យសកម្ម (Return on Assets)**

$$\text{Return on Assets} = \frac{\text{Net Income}}{\text{Total Assets}}$$

តារាងទី២១៖ អនុបាតផលចំណេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Net Income | 5,022 | 3,857 |
| B. Total Assets | 228,034 | 216,658 |
| Return on Assets | 2.2% | 1.78% |
| Change | - | -0.42% |

ក្រាហ្វិចទី១៣៖ អនុបាតផលចំណេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




ផលធៀបរវាងប្រាក់ចំណេញ និងទ្រព្យសកម្មសរុប នៅក្នុងឆ្នាំ ២០១៩ ស្មើនឹង ២,២% មានន័យថារាល់ការវិនិយោគ ១០០ អឺរ៉ូទៅលើទ្រព្យសកម្មនោះក្រុមហ៊ុនអាចបង្កើតប្រាក់ចំណេញបាន ២,២ អឺរ៉ូ ហើយរាល់ ១០០ អឺរ៉ូ នៃការវិនិយោគលើទ្រព្យសកម្មក្នុងឆ្នាំ ២០២០ ក្រុមហ៊ុនអាចបង្កើតបានប្រាក់ចំណេញ ១,៧៨ អឺរ៉ូ ដែលបានថយចុះ ០,៤២ អឺរ៉ូ។

### ឃ.អនុបាតប្រាក់ចំណេញធៀបនឹងមូលធន (Return on Equity)

$$\text{Return on Equity} = \frac{\text{Net Income}}{\text{Total Equity}}$$

តារាងទី២២៖ អនុបាតផលចំណេញធៀបនឹងមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Net Income | 5,022 | 3,857 |
| B. Total Equity | 59,907 | 61,520 |
| A/B. Return on Equity | 8.38 | 6.27 |
| Change | - | -2.11 |

ក្រាហ្វិចទី១៤៖ អនុបាតផលចំណេញធៀបនឹងមូលធនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




នៅក្នុងឆ្នាំ ២០១៩ ផលធៀបរវាងប្រាក់ចំណេញសុទ្ធ និងមូលធនសរុប ស្មើនឹង ៨,៣៨% មានន័យថារាល់ ១០០ អឺរ៉ូនៃការដាក់មូលធនសរុប ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណេញបាន ៨,៣៨ អឺរ៉ូ ហើយនៅឆ្នាំ ២០២០ ក្រុមហ៊ុនអាចបង្កើតប្រាក់ចំណេញបាន ៦,២៧ អឺរ៉ូ ដែលថយចុះ ២,១១អឺរ៉ូ។

**ង.អនុបាតប្រាក់ចំណេញក្នុងមួយហ៊ុន (Earnings Per Share) EPS**

$$\text{Earnings per Share} = \frac{\text{Profit attributable to common stock}}{\text{Number of common stock}}$$

តារាងទី២៣៖ អនុបាតប្រាក់ចំណេញក្នុងមួយហ៊ុនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019<br>(€ million) | 2020<br>(€ million) |
|---|---|---|
| A. Profit attributable to common stock | 4,494,400,000 | 3,448,100,000 |
| B. Number of common stock | 601,995,196 | 601,995,196 |
| A/B. Earnings per share | 7.47 | 5.73 |
| Change | - | -1.74 |

ប្រភព: យកចេញពីរបាយការណ៍ប្រចាំឆ្នាំរបស់ ក្រុមហ៊ុន BMW AG ឆ្នាំ ២០២០ (មើលឧបសម្ព័ន្ធទី៣)

ក្រាហ្វិចទី១៥៖អនុបាតប្រាក់ចំណេញក្នុងមួយហ៊ុនរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




យោងតាមទិន្នន័យខាងលើ យើងអាចសន្និដ្ឋានបានថានៅឆ្នាំ ២០១៩ ម្ចាស់ភាគហ៊ុនធម្មតាទទួលបានប្រាក់ចំណេញ ៧,៤៧ អឺរ៉ូក្នុងមួយហ៊ុន ហើយនៅឆ្នាំ ២០២០ ប្រាក់ចំណេញក្នុងមួយហ៊ុនបានថយចុះមកត្រឹមតែ ៥,៧៣ អឺរ៉ូ ដែលមានការថយចុះអស់ ១,៧៤ អឺរ៉ូបើធៀបនឹងឆ្នាំ ២០១៩។

### ច.អនុបាតថ្លៃជាមួយនឹងប្រាក់ចំណេញ (Price-Earnings Ratio) PE

$$\text{Price-Earnings Ratio} = \frac{\text{Market Price per Share}}{\text{Earnings per Share}}$$

តារាងទី២៤៖ អនុបាតថ្លៃជាមួយប្រាក់ចំណេញរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០

| | 2019 (€ million) | 2020 (€ million) |
|---|---|---|
| A. Market Price per Share | 73.14 | 72.23 |
| B. Earnings per Share | 7.47 | 5.73 |
| A/B. Price Earnings Ratio | 9.8 | 12.6 |
| Change | - | +2.8 |

ក្រាហ្វិចទី១៦៖ អនុបាតថ្លៃជាមួយប្រាក់ចំណេញរបស់ក្រុមហ៊ុន BMW AG ឆ្នាំ ២០១៩ និងឆ្នាំ ២០២០




នៅក្នុងឆ្នាំ ២០១៩ ដើម្បីទទួលបានប្រាក់ចំណេញ ១ អឺរ៉ូក្នុង ១ ហ៊ុនអ្នកវិនិយោគហ៊ានចំណាយដល់ទៅ ៩,៨ អឺរ៉ូក្នុងការវិនិយោគទៅលើភាគហ៊ុនក្នុងមួយហ៊ុន។ ចំណែកនៅក្នុងឆ្នាំ ២០២០ វិញដើម្បីទទួលបានប្រាក់ចំណេញ ១ អឺរ៉ូអ្នកវិនិយោគហ៊ានចំណាយដល់ទៅ ១២,៦ អឺរ៉ូក្នុងការវិនិយោគទៅលើភាគហ៊ុនក្នុងមួយហ៊ុន ដែលចំនួននេះមានការកើនឡើង ២,៨អឺរ៉ូ បើធៀបនឹងឆ្នាំ ២០១៩។ កំណើននៃ PE នេះបញ្ជាក់ឲ្យឃើញថាអ្នកវិនិយោគរំពឹងថាក្រុមហ៊ុននឹងរីកចម្រើនខ្លាំងនៅពេលអនាគត។

សរុបសេចក្តីមក យោងទៅតាមលទ្ធផលនៃការវិភាគខាងលើ យើងអាចសន្និដ្ឋានបានថា លទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ក្រុមហ៊ុនមានការថយចុះ ដែលបណ្តាលមកពីការថយចុះនៃការបង្កើតចំណូលដោយប្រើប្រាស់ទ្រព្យសកម្ម ហើយនិងមកពីការគ្រប់គ្រងចំណាយពុំសូវបានល្អក្នុងឆ្នាំ ២០២០។ បញ្ហាទាំងនេះបានធ្វើឲ្យប្រាក់ចំណេញដែលបានមកពីការវិនិយោគទៅលើទ្រព្យសកម្ម ក៏ដូចជាមូលធនរបស់ម្ចាស់ភាគហ៊ុននៅក្នុងឆ្នាំ ២០២០ មានការថយចុះផងដែរ។

## ៣.៤.លទ្ធផលនៃការវិភាគ

បន្ទាប់ពីបានសិក្សាស្វែងយល់ពីទិដ្ឋភាពទូទៅ ព្រមទាំងវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន BMW AG តាមជួរដេក ជួរឈរ និងតាមអនុបាតនៅឆ្នាំ ២០២០ ធៀបនឹងឆ្នាំ ២០១៩ យើងសង្កេតឃើញថាមានចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដែលបានកើតឡើងលើក្រុមហ៊ុននេះដូចជា៖

**ចំណុចខ្លាំង**

- ក្រុមហ៊ុន BMW AG ជាក្រុមហ៊ុនមួយដែលល្បីឈ្មោះ ហើយមានអតិថិជននៅជុំវិញពិភពលោក។
- ក្រុមហ៊ុនមានរថយន្តច្រើនប្រភេទដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន។
- បំណុលរយៈពេលខ្លី និងវែងមានការថយចុះនៅឆ្នាំ ២០២០ បើធៀបនឹងឆ្នាំ ២០១៩ (ដោយផ្អែកតាមការវិភាគតាមជួរដេកលើតារាងតុល្យការ)។
- មូលធនរបស់ក្រុមហ៊ុនមានការកើនឡើងនៅឆ្នាំ ២០២០ បើប្រៀបជាមួយឆ្នាំ ២០១៩។
- តាមរយៈការវិភាគលើអនុបាតចរន្ត អនុបាតរហ័ស យើងសង្កេតឃើញថាលទ្ធភាពទូទាត់បំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុនមានការកើនឡើងក្នុងឆ្នាំ ២០២០ បើប្រៀបធៀបជាមួយឆ្នាំ ២០១៩ មួយវិញទៀតចំពោះការលក់សន្និធិ និងការប្រមូលឥណទេយ្យរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ ២០២០ មានភាពល្អប្រសើរជាងឆ្នាំ ២០១៩។
- អនុបាតបំណុលធៀបជាមួយទ្រព្យសកម្ម បំណុលធៀបជាមួយមូលធន និង អនុបាតមេគុណមូលធននៅឆ្នាំ ២០២០ មានការថយចុះជាងឆ្នាំ ២០១៩ ដែលបញ្ជាក់ឲ្យឃើញថាក្រុមហ៊ុនអាចមានលទ្ធភាពទូទាត់បំណុលបានល្អប្រសើរជាង ហើយមួយវិញទៀតបើពឹងផ្អែកទៅលើអនុបាតទូទាត់ការប្រាក់នៅឆ្នាំ ២០២០ ក៏អាចទូទាត់ការប្រាក់បានច្រើនដងជាងឆ្នាំ ២០១៩ ដែរ។ ជាសរុបយើងអាចសន្និដ្ឋានថាសមត្ថភាពទូទាត់បំណុលរបស់ក្រុមហ៊ុននៅឆ្នាំ ២០២០ គឺល្អប្រសើរជាងឆ្នាំ ២០១៩។

## ចំណុចខ្សោយ

- តាមរយៈការវិភាគតាមជួរដេក យើងឃើញថាចំណូលពីការលក់នៅឆ្នាំ ២០២០ មានការថយចុះបើប្រៀបធៀបនឹងឆ្នាំ ២០១៩។
- ប្រាក់ចំណេញសរុបរបស់ក្រុមហ៊ុនមានការថយចុះបើធៀបនឹងឆ្នាំ ២០១៩ (ដោយផ្អែកលើការវិភាគតាមជួរដេករបស់របាយការណ៍លទ្ធផល)។
- យោងតាមការវិភាគតារាងតុល្យការលើជួរដេក យើងសង្កេតឃើញថាទ្រព្យសកម្មសរុបរបស់ក្រុមហ៊ុននៅឆ្នាំ ២០២០ មានការថយចុះបើធៀបនឹងឆ្នាំ២០១៩ ដោយសារតែ ទ្រព្យសកម្មរយៈពេលខ្លី និងទ្រព្យសកម្មរយៈពេលវែងមានការថយចុះ។
- ចំណូលពីការប្រើប្រាស់ទ្រព្យសកម្មក្នុងឆ្នាំ ២០២០ មានការថយចុះចំនួន ០,០១ អឺរ៉ូ បើប្រៀបធៀបនឹងឆ្នាំ ២០១៩ (ដោយសំអាងលើអនុបាតបង្វិលទ្រព្យសកម្ម)។
- តាមរយៈការវិភាគអនុបាតប្រាក់ចំណេញរបស់ក្រុមហ៊ុនក្នុងឆ្នាំ ២០២០ យើងឃើញថាប្រាក់ចំណេញមានការថយចុះ ០,៩២ អឺរ៉ូ ការធ្លាក់ចុះនេះបង្ហាញថាសមត្ថភាពគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុននៅឆ្នាំ ២០២០ នេះមិនសូវបានល្អបើធៀបនឹងឆ្នាំ ២០១៩។
- ប្រាក់ចំណេញពីទ្រព្យសកម្មរបស់ក្រុមហ៊ុនក្នុងឆ្នាំ ២០២០ មានការថយចុះ ០,៤២ អឺរ៉ូ បើប្រៀបធៀបនឹងឆ្នាំ ២០១៩ ។
- យើងសង្កេតឃើញថាផលចំណេញពីមូលធនម្ចាស់ភាគហ៊ុនក្នុងឆ្នាំ ២០២០ មានការថយចុះចំនួន ២,១១ អឺរ៉ូបើធៀបនឹងឆ្នាំ ២០១៩។ វាបង្ហាញឱ្យឃើញថាសមត្ថភាពស្វែងរកប្រាក់ចំណេញរបស់ក្រុមហ៊ុនមានការថយចុះជាងឆ្នាំមុន។

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាពីស្ថានភាពទូទៅរបស់ក្រុមហ៊ុន BMW យើងសង្កេតឃើញថា BMW AG គឺជាក្រុមហ៊ុនល្បីមួយដែលផលិតរថយន្តឈានមុខគេ និងទទួលបានការគាំទ្រពីសំណាក់ប្រជាជនទូទាំងពិភពលោក។ ដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន BMW AG មានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែនៅឆ្នាំ ២០២០ នេះការលក់ចេញរបស់ក្រុមហ៊ុនមានការថយចុះដោយសារតែបញ្ហាវិបត្តិកូវីដ ១៩ធ្វើឱ្យការលក់នៅឆ្នាំ ២០២០ របស់ BMW Group បានត្រឹមតែ ២,៣២៤,៨០៩ គ្រឿង ថយចុះអស់ ៨,៤% បើធៀបនឹងឆ្នាំ ២០១៩។ ដោយសារតែវិបត្តិនេះហើយទើបធ្វើឱ្យចំណូលពីការលក់របស់ក្រុមហ៊ុនក្នុងឆ្នាំ ២០២០ មានការថយចុះ ប៉ុន្តែទោះជាបែបនេះក៏ដោយក៏ទីផ្សាររបស់ក្រុមហ៊ុននៅតែបន្តមានការកើនឡើងសឹងតែគ្រប់តំបន់ដែរ ជាពិសេសនៅក្នុងឆ្នាំ ២០២០ នេះប្រទេសចិនគឺជាទីផ្សារដ៏ធំបំផុតរបស់ក្រុមហ៊ុន BMW Group ដែលការលក់កើនឡើងខ្ពស់គួរឱ្យកត់សម្គាល់។

តាមរយៈការវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុនៅឆ្នាំ ២០២០ ដោយធៀបនឹងឆ្នាំ ២០១៩ តាមជួរដេក ជួរឈរ និងការវិភាគតាមអនុបាតរួចមកយើងមើលឃើញនូវចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានមួយចំនួនដែលមាននៅក្នុងប្រតិបត្តិការ និងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន BMW នេះ។ បើយើងក្រឡេកមើលលទ្ធភាពសងបំណុលរយៈពេលខ្លីរបស់ក្រុមហ៊ុនគឺមានការកើនឡើងជាងឆ្នាំ ២០១៩ ហើយលទ្ធភាពទូទាត់ការប្រាក់របស់ក្រុមហ៊ុនក៏មានការកើនឡើងផងដែរក្នុងឆ្នាំ ២០២០ ហើយការលក់សន្និធិ និងការប្រមូលឥណទេយ្យរបស់ក្រុមហ៊ុននៅក្នុងឆ្នាំ ២០២០ មានភាពល្អប្រសើរជាងឆ្នាំ ២០១៩ ផងដែរ។ ចំណែកឯមូលធនម្ចាស់ទ្រព្យក្នុងឆ្នាំ ២០២០ មានការកើនឡើងជាងឆ្នាំ ២០១៩បន្តិចដែរ។ ទន្ទឹមនឹងការរីកចម្រើននោះផងដែរក្រុមហ៊ុន BMW AG មានចំណុចមិនសូវល្អមួយចំនួនបានកើតឡើង មានដូចជា ចំណូលពីការលក់ថយចុះ ប្រាក់ចំណេញសរុបរបស់ក្រុមហ៊ុនថយចុះ ហើយអនុបាតប្រាក់ចំណេញ ផលចំណេញពីទ្រព្យសកម្ម និង ផលចំណេញពីមូលធនក៏មានការថយចុះផងដែរ។

សរុបសេចក្តីមកក្រុមហ៊ុន BMW AG គឺមានលទ្ធភាពសងបំណុលខ្ពស់ក្នុងឆ្នាំ ២០២០ ប៉ុន្តែលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណេញ និងការគ្រប់គ្រងចំណាយរបស់ក្រុមហ៊ុនគឺមានភាពពុំសូវល្អប្រសើរនោះទេ។

## ២.អនុសាសន៍

ក្រោយពីបានវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុន BMW AG រួចហើយយើងឃើញថាក្រុមហ៊ុនមានចំណុចខ្លាំង និងខ្វះខាតមួយចំនួន។ ចំណុចខ្លាំងនោះគឺវាជាដំណឹងល្អសម្រាប់ម្ចាស់បំណុលចាស់ និងថ្មីអាចឲ្យពួកគេផ្តល់ជាឥណទានរយៈពេលខ្លី និងវែងដល់ក្រុមហ៊ុនបន្ថែមទៀត។ ចំណែកឯចំណុចខ្វះខាតវិញគឺ

សម្រាប់ម្ចាស់ភាគហ៊ុន និងអ្នកវិនិយោគដែលមានបំណងចង់ទិញហ៊ុនគួរតែពិចារណាក្នុងការទិញហ៊ុន ដោយសារតែលទ្ធភាពស្វែងរកប្រាក់ចំណេញរបស់ក្រុមហ៊ុនមានការថយចុះ ហើយការគ្រប់គ្រងចំណាយវិញក៏ពុំសូវបានល្អដែរ ជាពិសេសនោះថ្លៃភាគហ៊ុនក្នុងមួយហ៊ុនមានការកើនឡើង។ ដូច្នេះហើយម្ចាស់ភាគហ៊ុន និងអ្នកវិនិយោគដែលមានបំណងចង់ទិញហ៊ុនគួរតែពិចារណាជាមុនសិនក្នុងការទិញភាគហ៊ុនរបស់ក្រុមហ៊ុន។

# ឯកសារយោង


1. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា១ (CIAS1)
2. BAYERISCHE MOTOREN WERKE AG (BMW.DE) Stock Historical Prices & Data https://finance.yahoo.com/quote/BMW.DE/history?p=BMW.DE
3. Belverd E. Needles Jr and Marian Powersm. 2007. Financial and Managerial Accounting. 8th Edition. Houghton Mifflin. USA
4. BMW Group Mission, Vision & Values: https://www.comparably.com/companies/bmw/mission
5. BMW –Wikipedia:https://en.wikipedia.org/wiki/History_of_BMW
6. Company Report – BMW Group: https://www.bmwgroup.com/en/investor-relations/company-reports.html
7. Five types of financial Statement: https://www.wikiaaccounting.com/five-types-of-financial-statements-ifrs/
8. John J. Wild, Leopold A. Bernstein, K.R.Subramanyam. 2009. Financial Statement Analysis. USA
9. Peter M. Bergevin. 2001. Financial Statement Analysis. International Edition. Prentice Hall USA
10. Ross, Westerfield, Jordan. 2008. Fundamentals of Corporate Finance. 8th Edition. McGraw-Hill. USA
11. Weygandt, Kimmel & Kieso. 2014. Financial Accounting. 9thEdition. John Wiley & Sons, Inc. USA.
12. Weygandt, Kimmel & Kieso. 2012. Accounting Principle. 10th Edition. Wiley USA
13. Weygandt, Kimmel & Kieso. 2015 Financial Accounting. 3th IFRS Edition. Wiley USA

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** របាយការណ៍លទ្ធផលរបស់ក្រុមហ៊ុន BMW AG

# INCOME STATEMENT FOR GROUP AND SEGMENTS

| in € million | Note | Group | | Automotive (unaudited supplementary information) | |
|---|---|---|---|---|---|
| | | 2020 | 2019 | 2020 | 2019 |
| Revenues | 7 | 98,990 | 104,210 | 80,853 | 91,682 |
| Cost of sales | 8 | −85,408 | −86,147 | −71,456 | −78,062 |
| Gross profit | | 13,582 | 18,063 | 9,397 | 13,620 |
| Selling and administrative expenses | 9 | −8,795 | −9,367 | −7,237 | −7,762 |
| Other operating income | 10 | 916 | 1,031 | 931 | 976 |
| Other operating expenses | 10 | −873 | −2,316 | −929 | −2,335 |
| Profit / loss before financial result | | 4,830 | 7,411 | 2,162 | 4,499 |
| Result from equity accounted investments | 24 | 920 | 136 | 920 | 136 |
| Interest and similar income | 11 | 116 | 179 | 236 | 420 |
| Interest and similar expenses | 11 | −458 | −499 | −613 | −737 |
| Other financial result | 12 | −186 | −109 | 17 | 149 |
| Financial result | | 392 | −293 | 560 | −32 |
| Profit / loss before tax | | 5,222 | 7,118 | 2,722 | 4,467 |
| Income taxes | 13 | −1,365 | −2,140 | −713 | −1,354 |
| Profit / loss from continuing operations | | 3,857 | 4,978 | 2,009 | 3,113 |
| Profit / loss from discontinued operations | | – | 44 | – | 44 |
| Net profit / loss | | 3,857 | 5,022 | 2,009 | 3,157 |
| Attributable to minority interest | | 82 | 107 | 17 | 30 |
| Attributable to shareholders of BMW AG | 31 | 3,775 | 4,915 | 1,992 | 3,127 |
| Basic earnings per share of common stock in € | 14 | 5.73 | 7.47 | | |
| Basic earnings per share of preferred stock in € | 14 | 5.75 | 7.49 | | |
| Dilutive effects | | – | – | | |
| Diluted earnings per share of common stock in € | 14 | 5.73 | 7.47 | | |
| Diluted earnings per share of preferred stock in € | 14 | 5.75 | 7.49 | | |

**ឧបសម្ព័ន្ធទី២៖** តារាងតុល្យការរបស់ក្រុមហ៊ុន BMW AG

# BALANCE SHEET FOR GROUP AND SEGMENTS

| in € million | Note | Group 2020 | Group 2019 | Automotive (unaudited supplementary information) 2020 | Automotive (unaudited supplementary information) 2019 |
|---|---|---|---|---|---|
| ASSETS | | | | | |
| Intangible assets | 21 | 12,342 | 11,729 | 11,809 | 11,212 |
| Property, plant and equipment | 22 | 21,850 | 23,245 | 21,371 | 22,749 |
| Leased products | 23 | 41,995 | 42,609 | – | – |
| Investments accounted for using the equity method | 24 | 3,585 | 3,199 | 3,585 | 3,199 |
| Other investments | | 735 | 703 | 4,711 | 5,144 |
| Receivables from sales financing | 25 | 48,025 | 51,030 | – | – |
| Financial assets | 26 | 2,644 | 1,370 | 559 | 131 |
| Deferred tax | 13 | 2,459 | 2,194 | 3,196 | 3,451 |
| Other assets | 28 | 1,216 | 1,325 | 2,861 | 2,203 |
| Non-current assets | | 134,851 | 137,404 | 48,092 | 48,089 |
| Inventories | 29 | 14,896 | 15,891 | 13,391 | 14,404 |
| Trade receivables | 30 | 2,298 | 2,518 | 1,979 | 2,228 |
| Receivables from sales financing | 25 | 36,252 | 41,407 | – | – |
| Financial assets | 26 | 5,108 | 5,955 | 4,152 | 4,772 |
| Current tax | 27 | 606 | 1,209 | 342 | 1,000 |
| Other assets | 28 | 9,110 | 11,614 | 33,747 | 33,492 |
| Cash and cash equivalents | | 13,537 | 12,036 | 9,522 | 9,077 |
| Current assets | | 81,807 | 90,630 | 63,133 | 64,973 |
| Total assets | | 216,658 | 228,034 | 111,225 | 113,062 |

| in € million | Note | Group 2020 | Group 2019 | Automotive (unaudited supplementary information) 2020 | Automotive (unaudited supplementary information) 2019 |
|---|---|---|---|---|---|
| **EQUITY AND LIABILITIES** | | | | | |
| Subscribed capital | 31 | 660 | 659 | | |
| Capital reserves | 31 | 2,199 | 2,161 | | |
| Revenue reserves | 31 | 59,550 | 57,667 | | |
| Accumulated other equity | 31 | −1,518 | −1,163 | | |
| **Equity attributable to shareholders of BMW AG** | 31 | **60,891** | **59,324** | | |
| Minority interest | | 629 | 583 | | |
| **Equity** | | **61,520** | **59,907** | **41,117** | **40,174** |
| Pension provisions | 32 | 3,693 | 3,335 | 3,197 | 2,820 |
| Other provisions | 33 | 6,488 | 5,788 | 6,268 | 5,605 |
| Deferred tax | 13 | 509 | 632 | 697 | 543 |
| Financial liabilities | 35 | 67,390 | 70,647 | 2,087 | 2,680 |
| Other liabilities | 36 | 5,095 | 5,100 | 7,270 | 7,929 |
| **Non-current provisions and liabilities** | | **83,175** | **85,502** | **19,519** | **19,577** |
| Other provisions | 33 | 7,494 | 7,421 | 6,960 | 6,962 |
| Current tax | 34 | 747 | 963 | 537 | 704 |
| Financial liabilities | 35 | 38,986 | 46,093 | 897 | 1,929 |
| Trade payables | 37 | 8,644 | 10,182 | 7,365 | 8,814 |
| Other liabilities | 36 | 16,092 | 17,966 | 34,830 | 34,902 |
| **Current provisions and liabilities** | | **71,963** | **82,625** | **50,589** | **53,311** |
| **Total equity and liabilities** | | **216,658** | **228,034** | **111,225** | **113,062** |

**ឧបសម្ព័ន្ធទី៣៖** ចំនួនភាគហ៊ុនដែលបានបោះផ្សាយ និងការបែងចែកភាគលាភរបស់ក្រុមហ៊ុន BMW AG

## BMW AG STOCK

| | 2020 | 2019 | 2018 | 2017 | 2016 |
|---|---|---|---|---|---|
| **COMMON STOCK** | | | | | |
| Number of shares in 1,000 | 601,995 | 601,995 | 601,995 | 601,995 | 601,995 |
| Stock exchange price in €[1] | | | | | |
| Year-end closing price | 72.23 | 73.14 | 70.70 | 86.83 | 88.75 |
| High | 76.68 | 77.75 | 96.26 | 90.83 | 92.25 |
| Low | 37.66 | 58.70 | 69.86 | 77.71 | 65.10 |
| **PREFERRED STOCK** | | | | | |
| Number of shares in 1,000 | 57,689 | 56,867 | 56,127 | 55,605 | 55,114 |
| Stock exchange price in €[1] | | | | | |
| Year-end closing price | 55.20 | 55.05 | 62.10 | 74.64 | 72.70 |
| High | 57.60 | 67.85 | 85.50 | 78.89 | 74.15 |
| Low | 32.50 | 47.54 | 60.70 | 67.29 | 56.53 |
| **KEY DATA PER SHARE IN €** | | | | | |
| Dividend | | | | | |
| Common stock | 1.90[2] | 2.50 | 3.50 | 4.00 | 3.50 |
| Preferred stock | 1.92[2] | 2.50 | 3.52 | 4.02 | 3.52 |
| Earnings per share of common stock[3] | 5.73 | 7.47 | 10.60[5] | 13.07 | 10.45 |
| Earnings per share of preferred stock[4] | 5.75 | 7.49 | 10.62[5] | 13.09 | 10.47 |
| Free cash flow Automotive segment | 5.15 | 3.90 | 4.12 | 6.78 | 17.45 |
| Equity | 93.26 | 90.92 | 88.26[5] | 82.95 | 72.08 |

[1] Xetra closing prices.
[2] Proposed by management.
[3] Weighted average number of shares for the year.
[4] Stock weighted according to dividend entitlements.
[5] The 2018 figures were adjusted due to the change in accounting policy in conjunction with the adoption of IFRS 16 (see Annual Report 2019, Note 6 to the Group Financial Statements).